■ ក្នុងឆមាសទី១ ឆ្នាំ២០២១ មនុស្សជិត៦០នាក់បានស្លាប់ និងជាង៤០នាក់រងរបួសដោយសាររន្ទះបាញ់ <ទំព័រ៖៤

■ ពលករចំណាកស្រុកកម្ពុជាជាង ២០០,០០០នាក់ វិលត្រឡប់មកផ្ទះវិញ ក្នុងនោះជាង៤០ភាគរយជាស្ត្រី <ទំព័រ៖១០


# អ្នកនាំសារ the messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

ខែ កក្កដា | ឆ្នាំ ២០២១ | លេខទី ១៤១

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

JULY, 2021 | #141


ប្រទេសកម្ពុជា មានអ្នកឆ្លងវីរុសកូវីដ១៩បំប្លែងថ្មីប្រភេទដែលតា (Delta) សរុបចំនួន ៣៧៣១នាក់ ចាប់ពីចុងខែមីនា ដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ និងបានឆ្លងរាលដាលក្នុងរាជធានីខេត្តចំនួន២៤ លើកលែងតែខេត្តកែបប៉ុណ្ណោះដែលមិនទាន់មានករណីនេះ។ រាជធានីខេត្តទាំង២៤ដែលរកឃើញមានករណីវីរុសប្រភេទដែលតាមាននៅ៖ រាជធានីភ្នំពេញចំនួន ១២៥៦នាក់ ខេត្តឧត្តរមានជ័យចំនួន ២៨៧នាក់ សៀមរាប ២៣១នាក់ បន្ទាយមានជ័យ ៨២៧នាក់ ប៉ៃលិន ២៧នាក់ ព្រះវិហារ ១៤៨នាក់ បាត់ដំបង ១០៦នាក់ ស្វាយរៀង ៥៦នាក់ កំពង់ធំ ៦៧នាក់ ត្បូងឃ្មុំ ១២៤នាក់ កំពង់ចាម ៦៦នាក់ រតនៈគិរី ១០នាក់ កំពង់ស្ពឺ ២០នាក់ កណ្ដាល ១៥៩នាក់ ព្រៃវែង ៤នាក់ កំពត ៨នាក់ ស្ទឹងត្រែង ១៣៨នាក់ កំពង់ឆ្នាំង ២៣នាក់ ពោធិសាត់ ២៥នាក់ កោះកុង ១១នាក់ មណ្ឌលគិរី ៤៨នាក់ ព្រះសីហនុ ៤១នាក់ និងខេត្ត តាកែវ ចំនួន ៤៨នាក់ និងខេត្តក្រចេះចំនួន១នាក់។






■ នាយករដ្ឋមន្ត្រីជឿជាក់ថា កម្ពុជានឹងយកឈ្នះសមរភូមិជំងឺកូវីដ១៩ ក្រោមការចូលរួមដ៏សកម្មរបស់ពលរដ្ឋគ្រប់រូប ទំព័រ-៣

■ ចំណូលពន្ធគយឆមាសទីមួយដើមឆ្នាំថយចុះជិត៩ភាគរយ ទំព័រ-៩

# ជំនឿ សេចក្តីស្រឡាញ់ និងការវិនិច្ឆ័យ




លោកអ្នកជាទីរាប់អាន! ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងខែកក្កដាមានច្រើនរាប់មិនអស់ ទាំងអ្វីៗដែលនាំឱ្យយើងភ័យខ្លាច នាំឱ្យព្រួយ និងមានសញ្ញាដែលនាំឱ្យមានសង្ឃឹមផងដែរ។

ព្រឹត្តិការណ៍នៃមេរោគឆ្លងកូវីដ-១៩ បានជំរុញឱ្យម្នាក់ៗមានការភ័យខ្លាចកាន់តែខ្លាំង មានអ្នកស្លាប់កាន់តែច្រើន មានកន្លែងច្រើនឡើងៗផ្ទុះការឆ្លងមេរោគដ៏សាហាវនេះ មានអ្នកខ្លះឆ្លង អ្នកខ្លះមានញាតិមិត្ត បានស្លាប់ជាបន្តបន្ទាប់។ មនុស្សជាទីស្រលាញ់របស់ខ្លួនជាច្រើន បានចាកចេញទៅបានដោយគ្មានបងប្អូន ញាតិមិត្តជូនដំណើរជាដើម...។ សេចក្តីនេះនាំឱ្យយើងម្នាក់ៗមានសេចក្តីសង្វេក ភ័យខ្លាច មិនទុក ចិ ត្តគ្នា ខ្លាចរអាគ្នាទៅវិញទៅមក។ ចំពោះមុខ វិធានជាច្រើនបានដាក់ចេញដោយអាជ្ញាធរ និងក្រសួងសុខាភិបាល ដើម្បីការពារ និងកាត់បន្ថយការចម្លងមេរោគសាហាវនេះ។ យើងបានចាំ រត់មាត់ «៣កុំ និង ៣ការពារ» ដែលម្នាក់ៗត្រូវតែប្រកាន់យកអនុវត្តជាប់ជានិច្ច។

ក្នុងកាលៈទេសៈនេះ គ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិក ក្រុមជំនុំ ក៏ដូចជាបរិស័ទនៃសាសនាផ្សេងៗទៀត មិនមានការជួបជុំ បំពេញសេចក្តីជំនឿរបស់ខ្លួននោះឡើយ។

ក្នុងរយៈពេលនេះ ម្នាក់ៗខិតខំតាមរបៀបរៀងៗខ្លួនក្នុងការស្វែងរកយល់អំពីជំនឿរបស់ខ្លួន។ មានបងប្អូនមួយចំនួនបានចោទសួរថា តើព្រះជាម្ចាស់នៅឯណា? ហេតុអ្វីបង្កឱ្យពិភពលោកជួបរឿបបែបនេះ? អ្នកខ្លះក៏បាននិយាយបែបសុទិត្ថិនិយមថា នេះជាការពិន័យរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោកវិញ ដែលបានបំផ្លាញស្នាមព្រះហស្តរបស់ព្រះអង្គនៅលើផែនដីនេះស្ទើរលាយគ្មានសល់ និងតម្កើងខ្លួនឱ្យស្មើនឹងព្រះជាម្ចាស់។

ទោះបីជាយ៉ាងណា ទាំងនេះក៏នាំឱ្យម្នាក់ៗត្រូវត្រិះរិះពិចារណាផងដែរអំពី ជំនឿ សេចក្តីស្រលាញ់ និងការវិនិច្ឆ័យ។

### *ជំនឿត្រូវវិនិច្ឆ័យដែរឬទេ? សេចក្តីស្រលាញ់ត្រូវការវិនិច្ឆ័យដែរឬទេ?*

ពិតណាស់! ជំនឿនាំឱ្យយើងម្នាក់ៗមានសេចក្តីសង្ឃឹម។ ការវិនិច្ឆ័យ ជាចំណុចស្នូល និងមានសារសំខាន់ក្នុងជំនឿរបស់យើង។ ជំនឿដែលគ្មានត្រិះរិះ ងងឹតងងល់ នាំឱ្យយើងមិនបានស្គាល់ព្រះជាម្ចាស់ដ៏ពិតប្រាកដនោះទេ។ ការវិនិច្ឆ័យចំណុចស្នូល ព្រោះថា មានតែព្រះជាម្ចាស់ប៉ុណ្ណោះ ដែលវិនិច្ឆ័យមនុស្សគ្រប់រូប។ បើយើងវិនិច្ឆ័យនរណាម្នាក់នៅលើផែនដីនេះ នោះយើងក៏នឹងទទួលការវិនិច្ឆ័យនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់នៅស្ថានបរមសុខដែរ។ ប៉ុន្តែត្រង់ចំណុចនេះ ត្រូវការចែកឱ្យបានដាច់ពីគ្នា ចំពោះសេចក្តីវិនិច្ឆ័យ និងការវែកញែក គឺថាដើម្បីស្រលាញ់ដ៏ពិតប្រាកដ ត្រូវការការវិនិច្ឆ័យរបស់ព្រះជាម្ចាស់។ សម្រាប់មនុស្សនៅក្នុងលោកិយ៍ត្រូវប្រកាន់យក គឺ ចៀសវាងការលាក់ពុត ត្រូវមានភាពស្មោះត្រង់ និងមានធម៌មេត្តាករុណា។

បងប្អូនជាទីស្រលាញ់! ក្នុងព្រះបន្ទូលដំណឹងល្អព្រះយេស៊ូបានបង្ហាញ និងធ្វើសក្ខីកម្មយ៉ាងជាក់ច្បាស់ ដើម្បីឱ្យយើងបានយល់អំពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មានបំណងសំខាន់ឱ្យយើងចេះស្រលាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រលាញ់មនុស្សលោក រហូតបូជាព្រះជន្មផ្ទាល់នៅលើឈើឆ្កាងដើម្បីសេចក្តីស្រលាញ់ដ៏ពិតប្រាកដ។ ចំពោះគ្រីស្តបរិស័ទដែលមានជំនឿលើព្រះគ្រីស្តយេស៊ូ ការស្រលាញ់ព្រះជាម្ចាស់ និងស្រលាញ់បងប្អូនឯទៀតៗជាសេចក្តីប៉ងប្រាថ្នា និងស្នូលសំខាន់ក្នុងជីវិតរបស់ជីវិតម្នាក់។ បើយើងស្រលាញ់បងប្អូន តើយើងត្រូវវិនិច្ឆ័យបងប្អូនឱ្យទៅជាអាក្រក់យ៉ាងដូច្នេះ? ត្រូវរិះគន់ទម្លាប់បងប្អូនដែលព្រះជាម្ចាស់ស្រលាញ់ និងចាត់ឱ្យបានមកជួបនឹងយើងយ៉ាងដូច្នេះកើត?

ក្នុងបបូរមាត់របស់មនុស្សគ្រប់រូប ព្រះជាម្ចាស់បានប្រទានឱ្យមានសិរីល្អ ចាប់តាំងពីចាប់ក្នុងផ្ទៃម្តាយមកម្ល៉េះ។ ឱ្យចេះបិទបើក បញ្ចេញសូរសៀង យ៉ាងល្អប្រពៃ។ ក្នុងលិខិតរបស់សន្តប៉ូល ដែលនិយាយអំពីសេចក្តីស្រលាញ់បានបញ្ជាក់ច្បាស់ណាស់ ១កូរិនថូស១៌។

ក្នុងសេចក្តីខាងលើនេះមិនមែនមានន័យថា មិនឱ្យម្នាក់ៗមានការវែកញែក និងត្រិះរិះពិចារណានោះដែរ គឺត្រូវតែមានដើម្បីឱ្យដឹងអ្វីល្អ អ្វីអាក្រក់ អ្វីដែលមកពីព្រះវិញ្ញាណ អ្វីដែលមកពីអារក្សសាតាំង។

តាមលក្ខណៈមនុស្សរបស់ខ្ញុំ គឺងាយណាស់ក្នុងការរិះគន់បងប្អូន ក្នុងសហគមន៍ខ្ញុំ ធ្វើនេះត្រូវ នេះមិនត្រូវ បែបនេះល្អបែបនេះល្អជាង ប្រសើរជាង...។ ឬមួយទៀតខ្ញុំមានសមត្ថភាពពិសេស ក្នុងគិតរហ័ស អនុវត្តរហ័ស តែមិនបានស្តាប់ ឬទទួលយកគំនិតយោបល់របស់មនុស្សនៅជុំវិញខ្ញុំនោះឡើយ... ខ្ញុំគិតម្នាក់ឯងថា ខ្ញុំល្អលើសគេ ឬថាការបំពេញកិច្ចការរបស់អ្នកផ្សេងនឹងមិនប្រសើរឡើយ.. តើទាំងអស់នេះចេញមកពីខ្ញុំផ្ទាល់ ឬចេញមកពីសេចក្តីស្រលាញ់របស់ខ្ញុំចំពោះបងប្អូនដែលខ្ញុំកំពុងវិនិច្ឆ័យ និងរិះគន់នោះ? តើខ្ញុំជាមនុស្សមានពុត? ឬរិះគន់ឱ្យចម្រើន ឬនាំឱ្យមានការបាក់បែក? ពាក្យសំដីរបស់អ្នកចេះនិយាយពាក្យសរសើរ ឬចេះតែបណ្តុះបង្អាប់? តើខ្ញុំបានឆ្លុះបញ្ចាំងអំពីខ្លួនខ្ញុំផ្ទាល់ហើយឬនៅ? ក្រែងដូចក្នុងឃ្លាព្រះបន្ទូលរបស់ព្រះយេស៊ូ៖ «...មនុស្សមានពុតអើយ! ចូរយកធ្នឹមចេញពីភ្នែកអ្នកជាមុនសិន ទើបអ្នកមើលឃើញច្បាស់ ល្មមនឹងផ្តិតយកល្អងធូលីចេញពីភ្នែករបស់បងប្អូនអ្នកបាន»(ម៉ាថាយ ៧,១-៥)។

ព្រះយេស៊ូបានបង្រៀនឱ្យយើងចេះអធិដ្ឋានឃ្លាមួយបាននិយាយថា ៖ «...សូមលើកលែងទោសឱ្យខ្ញុំ ដូចខ្ញុំបានលើកលែងទោសឱ្យអស់អ្នកដែលបានប្រព្រឹត្តចំពោះខ្ញុំដែរ...»។ ទាំងនេះបញ្ជាក់ច្បាស់ថា មនុស្សត្រូវការការវិនិច្ឆ័យតាមរបៀបព្រះជាម្ចាស់ ក្នុងសេចក្តីស្រលាញ់ជានិច្ច មិនលាក់ពុត ត្រូវស្មោះត្រង់ និងមានមេត្តាករុណា។

ព្រះបន្ទូលនឹងជួយឱ្យយើងរឹងមាំ ព្រះវិញ្ញាណនឹងផ្តល់កម្លាំងដល់យើងជានិច្ច៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# នាយករដ្ឋមន្ត្រីជឿជាក់ថា កម្ពុជានឹងយកឈ្នះសមរភូមិជំងឺ កូវីដ១៩ ក្រោមការចូលរួមដ៏សកម្មរបស់ពលរដ្ឋគ្រប់រូប

*អត្ថបទ៖ ផល សុផានិត*



នាយករដ្ឋមន្ត្រីកម្ពុជា សម្តេចតេជោ ហ៊ុន សែន ជឿជាក់ថា ប្រទេសកម្ពុជានឹងយកជ័យជំនះលើវីរុសកូវីដ១៩ ក្រោមការចូលរួមសហការណ៍គ្នារបស់ប្រជាពលរដ្ឋម្នាក់ៗ នេះបើតាមសារពិសេសរបស់សម្តេចតេជោ ហ៊ុន សែន នៅក្នុងខួបលើកទី៧០ នៃថ្ងៃកំណើតគណបក្សប្រជាជនកម្ពុជា។

តាមរយៈសារលិខិតអបអរសាទរខួបកំណើតបក្ស នៅថ្ងៃទី ២៨ ខែមិថុនានេះ ក្នុងជាមេដឹកនាំបក្សនយោបាយធំជាងគេនៅកម្ពុជា និងជាអ្នកដឹកនាំនិងគ្រប់គ្រងជោគវាសនាជាតិអស់រយៈពេលជាង ៤ទសវត្សរ៍មកហើយនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានឆ្លៀតអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស អនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ឱ្យបានម៉ត់ចត់អំពីវិធានការនានាក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ។ ក្នុងនោះត្រូវចូលរួមចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ និងបន្តអនុវត្តវិធានការ «៣កុំ ៣ការពារ» ដើម្បីឱ្យជាតិកម្ពុជាអាចឆ្លងផុតកាលៈទេសៈដ៏លំបាកនៃការរាតត្បាតជំងឺកូវីដ១៩ បានឆាប់ ឈានទៅរកប្រក្រតីភាពឡើងវិញ តាមគន្លងថ្មីនៃជីវភាពសង្គម ផលិតកម្ម មុខរបរ និងការងាររបស់ប្រជាជន។

គិតត្រឹមថ្ងៃទី២៨ ខែកុម្ភៈ នេះ កម្ពុជា មានវ៉ាក់សាំងក្នុងដៃសម្រាប់ចាក់ជូនប្រជាពលរដ្ឋរហូតដល់ទៅ ១១លានដូស ហើយគ្រោងទទួលបានគ្រប់ ២០លានដូស ត្រឹមខែសីហា ឆ្នាំ២០២១ នេះ។ ជាមួយវត្តមានវ៉ាក់សាំងនេះ កម្ពុជា បានពន្លឿនការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋផងដែរ។

គិតថ្ងៃទី២៧ ខែមិថុនា ប្រជាពលរដ្ឋជិត ៤លាននាក់ ស្មើនឹងជិត ៤០ភាគរយ ត្រូវបានចាក់វ៉ាក់សាំងរួចរាល់។ លទ្ធផលនៃការចាក់វ៉ាក់សាំងនេះ ធ្វើឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់លេខ២ នៅអាស៊ាន ជាប្រទេសចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋបានច្រើន។ លទ្ធផលនេះ នាំឱ្យអង្គភាពសុខភាពពិភពលោក និងអង្គការអន្តរជាតិកោតសរសើរ និងវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន ផងដែរ។

ងាកទៅស្ថានភាពសេដ្ឋកិច្ចវិញរយៈពេលពីរឆ្នាំនេះ ទោះជួបការលំបាកតែកម្ពុជានៅតែទ្រទ្រង់សេដ្ឋកិច្ចរបស់ខ្លួន ដោយទប់ស្កាត់មិនឱ្យមានអតិផរណា ហើយរាជរដ្ឋាភិបាលនៅតែមានលទ្ធភាពរកប្រាក់ចំណូលសម្រាប់បើកបៀវត្សរ៍ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងការទូទាត់បំណុលជូនប្រទេស ព្រមទាំងចំណាយផ្សេងៗ។

សូមបញ្ជាក់ថា កម្ពុជា បានជួបនូវការរាតត្បាតនៃជំងឺកូវីដ១៩ អស់រយៈពេលជាងមួយឆ្នាំមកហើយ។ ជាងមួយឆ្នាំមកនេះ កម្ពុជាមានអ្នកឆ្លងជំងឺសរុបជិត១០ម៉ឺននាក់ ស្លាប់ប្រមាណ ជាងពីរពាន់នាក់ និងព្យាបាលជាជាង៩ម៉ឺននាក់៕

# ប្រធានគណបក្សប្រជាជន ថ្លែងសារថ្ងៃ ខួបកំណើតទី៧០ ថ្ងៃបង្កើតគណបក្ស

*អត្ថបទ៖ ផល សុផានិត*

ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២១ នេះ ជាថ្ងៃខួបលើកទី៧០ (២៨ មិថុនា ១៩៥១-២៨ មិថុនា ២០២១) ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ក្នុងនោះសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងជាប្រធានគណបក្សប្រជាជនកម្ពុជា បានថ្លែងសារពិសេស នៃថ្ងៃកំណើតគណបក្សប្រជាជននេះ។

សម្តេចតេជោ ហ៊ុន សែន បានលើកឡើងក្នុងសារលិខិតថា ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ នេះ ជាថ្ងៃគម្រប់ខួបទី៧០ នៃការបង្កើតគណបក្សប្រជាជនកម្ពុជា ដែលមានឈ្មោះដើមថា បក្សប្រជាជនបដិវត្តខ្មែរ ដោយមានប្រភពពីចលនាតស៊ូស្នេហាជាតិរបស់ប្រជាជនកម្ពុជា ប្រឆាំងពួកអាណានិគមននិយម ដើម្បីឯករាជ្យជាតិ។

ក្នុងនាមជាគណបក្សរបស់ប្រជាជន អាស្រ័យដោយប្រជាជន និងដើម្បីប្រជាជន គណបក្សបានប្រកាន់ខ្ជាប់គោលបំណង និងឧត្តមគតិរបស់ខ្លួន គឺឈរនៅខាងប្រជាជន ផ្សារភ្ជាប់រួមសុខរួមទុក្ខជាមួយប្រជាជននៅគ្រប់កាលៈទេសៈ ពុះពារជម្នះគ្រប់ឧបសគ្គ ហ៊ានធ្វើ ពលិកម្មឥតរួញរា ដើម្បីប្រទេសកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម។

គណបក្សបានដឹកនាំប្រជាជន ធ្វើការតស៊ូប្រយុទ្ធយ៉ាងអង់អាចដើម្បីរំដោះប្រទេសជាតិ ការឈ្លានពានត្រួតត្រារបស់ពួកបរទេស និងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះជាតិឱ្យមានជីវិតរស់ឡើងវិញទាន់ពេលវេលា ដែលបានបញ្ចប់ទាំងស្រុងសម័យកាលដ៏ខ្មៅងងឹតបំផុតនៃកម្ពុជា ហើយបើកឡើងទំព័រប្រវត្តិសាស្ត្រថ្មី នៃការកសាងទឹកដីឡើងវិញ របស់ប្រជាជនយើងលើមាគ៌ាសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍។



សម្តេចតេជោ ហ៊ុន សែន បន្តថា រយៈពេល ៤២ ឆ្នាំកន្លងទៅនេះ បន្ទាប់ពីបានទទួលជ័យជម្នះលើរបបប្រល័យពូជសាសន៍ ប៉ុល ពត នាថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ គណបក្សប្រជាជនកម្ពុជា បានដឹកនាំប្រទេសសម្រេចបានសមិទ្ធផល ដ៏ធំធេងក្នុងបុព្វហេតុនៃការការពារការរស់ឡើងវិញរបស់ប្រជាជន រាំងស្កាត់ការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍, ការស្តារ និងកសាងប្រទេសឡើងវិញ ពីចំណុចសូន្យ និងពីបាតដៃទទេ ឱ្យមានស្ថិរភាពជាជំហានៗ បង្កើតបានបុព្វបទ និងលក្ខណសម្បត្តិជាមូលដ្ឋានសម្រាប់ការបង្រួបបង្រួមជាតិ, ការបង្កើតរដ្ឋធម្មនុញ្ញថ្មី និងព្រះរាជាណាចក្រកម្ពុជាទីពីរនាឆ្នាំ១៩៩៣, ការបង្កើតសន្តិភាពពេញលេញជូនជាតិ ចាប់ពីចុងឆ្នាំ១៩៩៨ មកតាមរយៈនយោបាយឈ្នះ ឈ្នះ, ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពរបស់ពលរដ្ឋ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចធ្វើឱ្យប្រជាជនមានជីវភាពកាន់តែប្រសើរឡើង ហើយកំពុងរួមរស់ជាមួយគ្នាយ៉ាងសុខដុមរមនា៕

## អ្នកថតរូបអំពីកម្ពុជាក្នុង ទ.វ ១៩៥០ និង១៩៦០ ជាតិបារាំង ដ៏ល្បីល្បាញ ម្នាក់ស្លាប់ ដោយសារកូវីដ ក្នុងជន្មាយុ ១០១ឆ្នាំ



*អត្ថបទ៖ CSC*

អ្នកថតរូបដ៏ល្បីល្បាញមួយរូបក្នុងទសវត្សទី៥០ និងទី៦០ គឺលោក រ៉េម៉ុង កូធ្យេ (Raymond Cauchetier) បានទទួលមរណភាព កាលពីខែកុម្ភៈ ឆ្នាំ២០២១នេះ ដោយសារជំងឺកូវីដ-១៩ ក្នុងអាយុ ១០១ឆ្នាំ នៅក្នុងក្រុងប៉ារីស ប្រទេសបារាំង។

លោកជាម្ចាស់ដើមនៃរូបថតអំពីរាជធានីភ្នំពេញ និងពីប្រទេសកម្ពុជាក្នុងទសវត្សឆ្នាំ១៩៥០ និងទសវត្សឆ្នាំ១៩៦០ ដែលល្បីល្បាញលើនៅបណ្តាញសង្គមសព្វថ្ងៃនេះ ដែលបានបង្ហាញឲ្យឃើញច្បាស់ ពីការរីកចម្រើន និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជានាសម័យនោះ។ ក្នុងរូបថតមួយសន្លឹកដែលបានបង្ហាញវត្តមានទេសភាពយ៉ាងស្អាតរបស់រមណីយដ្ឋានវត្តភ្នំ និងវិសាលព្រះវិហារ «ព្រះគ្រីស្តជាព្រះមហាក្សត្រ» របស់ព្រះសហគមន៍កាតូលិក ដែលនៅខាងក្រោយវត្តភ្នំ ក្នុងរាជធានីភ្នំពេញ ជារូបថតដ៏កម្របំផុត។

លោក រ៉េម៉ុង កូធ្យេ ក៏ធ្លាប់បានថ្វាយរូបថតជាស្នាដៃរបស់លោកពីប្រទេសកម្ពុជា ចំនួន ៣០០០ សន្លឹកថ្វាយជូនព្រះបរមរតនកោដ សម្តេចព្រះនរោត្តមសីហនុ ប៉ុន្តែរូបថតភាគច្រើន ត្រូវបានបំផ្លាញចោល ក្នុងរបបខ្មែរក្រហមអស់ហើយ។

លោក រ៉េម៉ុង កូធ្យេ កើតនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩២០ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ក្រោយសង្គ្រាមលោកលើកទី២បានបញ្ចប់ លោកបានចូលបម្រើកងទ័ពអាកាសបារាំងក្នុងសង្គ្រាមឥណ្ឌូចិន លើកទី១ ជាពេលលោកចាប់ផ្តើមកិច្ចការជាអ្នកថតរូប។ លោកបានបម្រើការងារក្នុងមុខងារជាអ្នកថតរូបសង្គ្រាម ក្នុងប្រទេសវៀតណាម។ បន្ទាប់ពីលោកឈប់ពីកងទ័ព លោកបន្តរស់នៅក្នុងតំបន់ឥណ្ឌូចិន និងបានថតរូបជាច្រើនក្នុងប្រទេសនានានៃតំបន់នេះ។ ជាពិសេសប្រទេសកម្ពុជា ដែលបានបង្ហាញជីវិតរស់នៅរបស់ប្រជាជន ការអភិវឌ្ឍប្រទេស ភាពរីកចម្រើន និងរួមទាំងរូបថតនៅអង្គរវត្តផងដែរ។ លោកក៏ធ្លាប់បានប្រឡូកក្នុងអាជីពជាអ្នកថតរូប ពី១៩៥៩ ដល់ឆ្នាំ ១៩៦៨ផងដែរ៕

## វ៉ាក់សាំងចិនស៊ីណូហ្វាម និងវ៉ាក់សាំងចិនស៊ីណូវ៉ាក់ ចានចូលក្នុងបញ្ជីឈ្មោះនៃយន្តការCOVAX ហើយ




*អត្ថបទ៖ អមរិទ្ធ ដានុត*

យោងតាមស្ថានទូតចិនប្រចាំកម្ពុជាបានឱ្យដឹងថា នាថ្ងៃទី១២ ខែកក្កដា សម្ព័ន្ធថ្នាំបង្ការសកល(GAVI)បានប្រកាសថា ខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញមុន(Pre Order)ជាមួយក្រុមហ៊ុន China National Pharmaceutical Group Corporation និងក្រុមហ៊ុន Sinovac Biotech។

ស្ថានទូតដដែលបានបញ្ជាក់ទៀតថា ៖ «នេះមានន័យថា វ៉ាក់សាំងចិនស៊ីណូហ្វាម និងវ៉ាក់សាំងចិនស៊ីណូវ៉ាក់បានចូលក្នុងបញ្ជីឈ្មោះនៃយន្តការCOVAX និងព្រមទាំងអាចផ្គត់ផ្គង់វ៉ាក់សាំងជូនដល់យន្តការCOVAX ដើម្បីប្រើប្រាស់ក្នុងកិច្ចទប់ស្កាត់ជំងឺវីរុស នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដោយចាប់ពីខែកក្កដានេះតទៅ»។

យោងតាមកិច្ចព្រមព្រៀងខាងលើ ក្រុមហ៊ុនចិនទាំងពីរនេះនឹងផ្គត់ផ្គង់វ៉ាក់សាំងកូវីដចំនួន១១០លានដូសទៅកាន់យន្តការ COVAXមុនចុងខែតុលាឆ្នាំនេះ នឹងបន្តផ្គត់ផ្គង់រយៈពេលវែងជាបន្តបន្ទាប់។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនចិនទាំងពីរនេះជាមួយនឹងសម្ព័ន្ធGAVI ជាការបង្ហាញពីលក្ខណៈសំខាន់នៃការអនុវត្តសកម្មភាពជាក់ស្តែងរបស់ចិនក្នុងការចាត់ទុកវ៉ាក់សាំងជាផលិតផលសាធារណៈ៕



## ក្នុងឆមាសទី១ ឆ្នាំ២០២១ មនុស្សជិត៦០នាក់ចាន ស្លាប់ និងជាង៨០នាក់រងរបួសដោយសាររន្ទះបាញ់

*អត្ថបទ៖ អមរិទ្ធ ដានុត*

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយបានឱ្យដឹងថា រយៈពេល ៦ ខែ ឆ្នាំ២០២១ នេះ ករណីរន្ទះបាញ់ បានកើតឡើងចំនួន៧០ ករណី ដែលបានបណ្តាលឱ្យមានមនុស្សស្លាប់ចំនួន៥៩នាក់ និងរងរបួសចំនួន៨៤នាក់ ដែលតួលេខនេះមានការកើនឡើង បើធៀបនឹងរយៈពេលដូចគ្នានឹងឆ្នាំ២០២០ ដែលមានចំនួន៦០ករណី។

របាយការណ៍ពីទិន្នន័យការប៉ះពាល់ និងខូចខាតដោយគ្រោះមហន្តរាយ ក្នុងឆមាសទី១ ឆ្នាំ២០២១ ដែល *អ្នកនាំសារ* ទទួលបាននៅថ្ងៃទី០៦ ខែកក្កដា បានលើកឡើងថា ករណីរន្ទះបាញ់នេះ បានកើតឡើងស្ទើរតែគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា ដោយក្នុងនោះខេត្តដែលមានករណីរន្ទះបាញ់ច្រើនជាងគេគឺខេត្តបាត់ដំបង ដែលមានរហូតដល់១៥ករណីនិងបានបណ្តាលឱ្យមនុស្សចំនួន១៤នាក់បានបាត់បង់ជីវិត និង៣នាក់រងរបួស។

ខេត្តដែលមានករណីរន្ទះបាញ់ច្រើនបន្ទាប់ពីខេត្តបាត់ដំបងគឺខេត្តកំពង់ធំ ដែលមានចំនួន ៧ករណី ក្នុងនោះមនុស្សស្លាប់ចំនួន៨នាក់ និង១០នាក់រងរបួស។

របាយការណ៍ដដែលនេះក៏បានឱ្យដឹងផងដែរថា ក្នុងរយៈពេល៦ខែដើមឆ្នាំ ២០២១នេះដែរ ករណីខ្យល់កន្ត្រាក់ក៏បានកើតមានច្រើនរហូតដល់១៣៨ លើក ដែលបណ្តាលឱ្យមានផ្ទះចំនួន៦០០ខ្នងដួលរលំ និងផ្ទះចំនួន៤៥៦៥ខ្នងទៀតរងការខូចខាតតិចតួច (របើកដំបូល)។

ប្រភពដដែលបានបញ្ជាក់ថា៖«ក្នុងករណីខ្យល់កន្ត្រាក់នេះដែរ ក៏បានបណ្តាលឱ្យមនុស្សចំនួន៥នាក់បានស្លាប់ និង៥៦នាក់ផ្សេងទៀត រងរបួស»។

មួយវិញទៀត ចំពោះករណីអគ្គិភ័យវិញ ក្នុងរយៈពេល៦ខែដូចគ្នានេះដែរ ក៏បានកើតមានឡើងគួរឱ្យកត់សម្គាល់ផងដែរ ដែលក្នុងនោះអគ្គិភ័យបានកើតឡើងរហូតដល់២៨៨លើកក្នុងរាជធានី-ខេត្តទាំង២៥ទូទាំងប្រទេសតែម្តង ដែលករណីកើតច្រើនជាងគេមានក្នុងរាជធានីភ្នំពេញចំនួន៥៩លើក ខេត្តបាត់ដំបងចំនួន២២លើក ខេត្តកណ្តាល ក្រចេះ កំពង់ចាម និងសៀមរាប ចំណែកខេត្តដែលមានអគ្គិភ័យកើតឡើងតិចជាងគេគឺខេត្តកែប ដែលមានតែ២លើកប៉ុណ្ណោះ។

គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយបានបញ្ជាក់ថា ៖ «ផ្ទះចំនួន៣២១ខ្នងត្រូវបានឆេះខូចខាតដោយអគ្គិភ័យ ក្នុងរយៈពេល៦ខែដើមឆ្នាំនេះ ឯតូបក្នុងផ្សារចំនួន៨០តូបក៏ត្រូវបានឆេះផងដែរ»។

របាយការណ៍ដដែលបានបន្តថា អគ្គិភ័យក៏បានកើតឡើងទៅលើរោងចក្រ-សិប្បកម្មចំនួន១១កន្លែង ឆេះឃ្លាំងទំនិញចំនួន១១ឃ្លាំង និងអគាររដ្ឋបាលនានាផ្សេងទៀតរហូតដល់១៧កន្លែងផងដែរ។

ប្រភពដដែលនេះបានបញ្ជាក់ថា ករណីអគ្គិភ័យនេះបានបណ្តាលឱ្យមនុស្សចំនួន១៤នាក់ស្លាប់ និង២៩នាក់បានរងរបួស៕

## កម្ពុជាលើកឡើងពីបញ្ហាប្រឈមរបស់ពិភពលោកក្នុងរយៈពេល២ឆ្នាំចុងក្រោយ

*អត្ថបទ៖ ផល សុផានិត*




សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចេញនៅថ្ងៃទី១៣ ខែកក្កដា បានបង្ហាញពីសេចក្តីថ្លែងការណ៍របស់លោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៅក្នុងសន្និសីទរដ្ឋមន្ត្រីពាក់កណ្តាលឆមាស នៃចលនាមិនចូលបក្សសម្ព័ន្ធ ស្តីពី«ចលនាមិនចូលបក្សសម្ព័ន្ធ នៅចំណុចនៃកិច្ចខិតខំប្រឹងប្រែងពហុភាគីក្នុងការឆ្លើយតបទៅនឹងការប្រឈមពិភពលោក»ថ្ងៃទី១៣ ដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ។

ក្នុងសេចក្តីថ្លែងការណ៍នោះ លោក ប្រាក់ សុខុន បានលើកឡើងថា នាពេលបច្ចុប្បន្ន ក្នុងចំណោមប ញ្ហាប្រឈមសំខាន់ៗ ដែលកំពុងញាំញីពិភពលោកក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ រួមនឹងការប្រ ណាំងប្រជែងភូមិសាស្ត្រនយោបាយរបស់មហាអំណាច ការផ្ទុះឡើងនៃជំងឺរាតត្បាតកូវីដ១៩ ដ៏កាចសាហាវ គឺជាដំណាក់កាលដ៏អាក្រក់បំផុតនៃវិបត្តិផ្នែកសុខភាព សេដ្ឋកិច្ច-សង្គមកិច្ច និងមនុស្សធម៌។

ការរើបកាន់តែខ្លាំងឡើងវិញនៃគ្រោះមហន្តរាយដោយធម្មជាតិ និងពីអាកាសធាតុ និងការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល ដែលអាចនឹងកើតមានឡើងនាពេលបន្ទាប់។

លោកបន្តថា កម្ពុជាជឿជាក់យ៉ាងមុតមាំថា ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមជាសកលទាំងនេះ ការខិតខំប្រឹងប្រែងកិច្ចសហប្រតិបត្តិការពហុភាគី គួរតែត្រូវបានបញ្ចូលជាមូលដ្ឋាននៅក្នុងប្រព័ន្ធបទប ញ្ញត្តិនានា ដោយស្របតាមគោលការណ៍បានឌុង សេចក្តីថ្លែងការណ៍បាគូឆ្នាំ២០១៩ និងធម្មនុញ្ញអង្គការសហប្រជាជាតិ។

លោកបានបន្ថែមថា ខណៈដែលសហគមន៍អន្តរជាតិព្យាយាមជម្នះផលប៉ះពាល់នៃជំងឺរាតត្បាត យើងត្រូវពង្រឹងគុណតម្លៃនៃពហុភាគីនិយម និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធា នាឱ្យប្រទេសទាំងអស់ទទួលបានវ៉ាក់សាំង និងឧបករណ៍វេជ្ជសាស្ត្រ ដោយគ្មានការរារាំង និងប្រកប ដោយសមភាព។

ភាពចាំបាច់នេះ មានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យប្រទេសជាសមាជិកចលនាមិនចូលបក្សសម្ព័ន្ធ ដើរលើមាគ៌ាស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ។

វិធីសាស្ត្រទិសដៅពីរបច្ចុប្បន្នរបស់ប្រទេសអភិវឌ្ឍន៍ប្រឆាំងនឹងប្រទេសកំពុងអភិវឌ្ឍន៍ អាចនឹងទទួលបរាជ័យដោយខ្លួនឯង។ក្នុងកិច្ចប្រ ជុំនេះ ឯកឧត្តមក៏បានលើកពីបញ្ហាគ្រោះមហន្តរាយធម្មជាតិ និងការប្រឈមនានាដែលកំពុងចួបប្រទះ ផងដែរ។

លោកក៏បានរម្លឹកផងដែរថា តាមប្រវត្តិសាស្ត្រ ចលនាមិនចូលបក្សសម្ព័ន្ធបានផ្តួចផ្តើមគំនិតនៃទំនាក់ទំនងអន្តរជាតិដែលជួយទប់ស្កាត់សង្គ្រាមលោកថ្មី។

លោកជឿជាក់ថា សព្វថ្ងៃនេះនៅក្នុងពិភពពហុភាគីនៃការក្រក្ខតប្រជែងប្រកបដោយគ្រោះថ្នាក់ គំនិតនៃការរួមរស់ដោយសន្តិសហវិជ្ជមាន ដូចដែលបានបង្កើតឡើងដោយសហស្ថាបនិកនៃចលនាមិនចូលបក្សសម្ព័ន្ធ គឺនៅតែមានភាពសមស្របជាងពេលណាទាំងអស់ ហើយគ្មានប្រទេសណាមួយដែលប្រសើរឬមានសមត្ថភាពជាងចលនាមិនចូលប ក្សសម្ព័ន្ធ ក្នុងការលើកកម្ពស់គំនិតនេះម្តងទៀតនោះទេ៕

# សម្តេចតេជោ ហ៊ុន សែន អំពាវនាវទៅគណបក្សទាំងអស់ ត្រូវប្រកាន់ឥរិយាបថស្ថាបនានិយមអំឡុងវិបត្តិកូវីដ-១៩នេះ

*អត្ថបទ៖ ផល សុផានិត*

សម្តេចតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជាដែលកំពុងដឹកនាំរាជរដ្ឋាភិបាលបានអំពាវនាវទៅគណបក្សនយោបាយទាំងអស់ឱ្យប្រកាន់យកឥរិយាបថថ្មីអំឡុងពេលពិភពលោកកំពុងជួបប្រទះនឹងវិបត្តិកូវីដ-១៩នេះ។




សម្តេចតេជោ ហ៊ុន សែន បានថ្លែងបែបនេះនៅក្នុងកិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំបក្សកុម្មុនីស្តចិន និងគណបក្សនយោបាយលើពិភពលោកដែលត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញនៅយប់នេះ។

ក្នុងសុន្ទរកថា សម្តេចតេជោ ហ៊ុន សែន បានស្នើឡើងនូវទស្សនទានរបស់សម្តេច ដោយអំពាវនាវឱ្យគណបក្សនយោបាយទាំងអស់លះបង់ចោលឥរិយាបថប្រណែនឈ្នានីស និងចាំតែរិះគន់គ្មានមូលដ្ឋាន ហើយជំនួយមកវិញនូវគំនិតបែបស្ថាបនិយមសម្រាប់ដោះស្រាយវិបត្តិកូវីដ-១៩ ។

សម្តេចតេជោ ហ៊ុន សែន ថ្លែងថា៖ «ក្នុងកាលៈទេសៈពោរពេញទៅដោយភាពប្រឈមដ៏ស្រួចស្រាល់នេះ គណបក្សនយោបាយ គួរតែប្រកាន់យកនូវការទទួលខុសត្រូវខ្ពស់ចំពោះជាតិ និងប្រជាជន ព្រមទាំងបញ្ឈប់ឱ្យបាននូវវប្បធម៌ និងឥរិយាបថប្រណែនឈ្នានីស ចាំតែមើលបំណាំចោទប្រកាន់ និងរិះគន់គ្មានមូលដ្ឋាន ដោយជំនួសមកវិញនូវឥរិយាបថបែបស្ថាបនានិយម និងស្មារតីនៃកិច្ចសហការក្នុងការដោះស្រាយបញ្ហាប្រឈមរបស់មនុស្សជាតិ និងប្រជាជនទាំងក្នុងក្របខណ្ឌពិភពលោក ក៏ដូចជាក្នុងប្រទេសនីមួយ»។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងបែបនេះចំពេលដែលពិភពលោកទាំងមូល រួមទាំងកម្ពុជាផងដែរ កំពុងប្រយុទ្ធនឹងការឆ្លងរីករាលដាលនៃមេរោគកូវីដ-១៩អស់រយៈពេលជាងមួយឆ្នាំមកហើយនោះ៕

# គ្រោះថ្នាក់ចរាចរណ៍ធ្លាក់ចុះ ២២ភាគរយក្នុងរយពេល៦ខែឆ្នាំនេះ

*អត្ថបទ៖ អមរិន្ទ ដានុត*

នៅក្នុងរយៈពេលឆមាសទី១ ឆ្នាំនេះ ករណីគ្រោះថ្នាក់ចរាចរណ៍ថយចុះ២២ ភាគរយ ឬស្មើនឹង ៣៥៨ ករណី។ នេះបើតាមការបញ្ជាក់របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។



សម្តេចក្រឡាហោម បន្ថែមថា នៅក្នុងរយៈពេល១ឆមាសនេះដែរ មានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ១២៦១លើក (ជាង៥០ភាគរយកើតឡើងពេលយប់) បណ្តាលឱ្យស្លាប់មនុស្ស៧០៩នាក់ និងរបួស ១៧៩២នាក់ ក្នុងនោះរបួសធ្ងន់១០៤៦នាក់។មូលហេតុនៃគ្រោះថ្នាក់ គឺពាក់ព័ន្ធនឹងល្បឿន៣៤ភាគរយ មិនគោរពសិទ្ធិ២៣ភាគរយ បត់៩ភាគរយ មិនប្រកាន់ស្តាំ១៦ភាគរយ វ៉ាជែង៨ភាគរយ ស្រវឹង៣ភាគរយ យានយន្ត៣ភាគរយ និងងងុយ១ភាគរយ។

សម្រាប់រយៈពេល៦ខែដើមឆ្នាំនេះ ភូមិសាស្ត្រដែលមានអត្រាគ្រោះថ្នាក់ច្រើន គឺរាជធានីភ្នំពេញ ដែលមានគ្រោះថ្នាក់៣៤០លើក ខេត្តកណ្តាល៨៦លើក និងខេត្តស្វាយរៀង៧៧លើក។ ចំណែកគ្រោះថ្នាក់រថយន្តដឹកកម្មករវិញ បានកើតមានឡើងនៅខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងតាកែវ ដែលបណ្តាលឱ្យកម្មកររបួសសរុបចំនួន២៧៦នាក់។ បញ្ហាប្រឈម គឺបទល្មើសមិនពាក់មួកសុវត្ថិភាព ខ្សែក្រវ៉ាត់ និងល្មើសល្បឿននៅតែមានអត្រាខ្ពស់ ខណៈក្នុងចំណោមជនរងគ្រោះដែលស្លាប់មាន៧៨ភាគរយជាអ្នកជិះម៉ូតូ និង៦៩ភាគរយមិនពាក់មួកសុវត្ថិភាព។

ជាមួយគ្នានេះ ក្នុងរយៈពេល៦ខែដើមឆ្នាំនេះ សមត្ថកិច្ចបានត្រួតពិនិត្យយានយន្តសរុបចំនួន១០២,៩៩៥គ្រឿង រួមមានម៉ូតូល្មើសចំនួន៧៧,៧៩៤គ្រឿង ក្នុងចំណោមនោះការល្មើសដោយសារមិនពាក់មួកសុវត្ថិភាពមាន៩០ភាគរយ សញ្ញាចរាចរណ៍៦ភាគរយ ផ្លាកលេខ២ភាគរយ ទូរស័ព្ទ២ភាគ និងបើកបរទាំងស្រវឹង១ភាគរយ។ រកឃើញរថយន្តល្មើសចំនួន ២៨,២០១គ្រឿង (រថយន្តធំជាង៦០០គ្រឿង) ហើយក្នុងចំណោមនោះរថយន្តល្មើសខ្សែក្រវ៉ាត៥២ភាគរយ ល្បឿន១៦ភាគរយ ទូរស័ព្ទ១០ភាគរយ សញ្ញាចរាចរណ៍៧ភាគរយ ផ្លាកលេខ៥ភាគរយ ល្មើសចំណុះ៤ភាគរយ បណ្ណបើកបរ៤ភាគរយ ស្រវឹង១ភាគរយ ឆៀក១ភាគរយ និងអាជីវកម្ម១ភាគរយ។

សម្តេចក្រឡាហោម ស ខេង ក៏បានអំពាវនាវជនរួមជាតិទាំងអស់សូមប្រកាន់យកការបើកបរដោយគោរពច្បាប់ចរាចរណ៍ឱ្យគ្រប់ៗគ្នា និងគ្រប់មធ្យោបាយធ្វើដំណើរ ព្រមទាំងមានស្មារតីប្រុងប្រយ័ត្នឱ្យបានខ្ពស់ និងគ្រប់ពេលវេលា៕

# រាជរដ្ឋាភិបាលជប៉ុនផ្តល់វ៉ាក់សាំង AstraZeneca ចំនួនប្រមាណ១លានដូសដល់កម្ពុជា



*អត្ថបទ៖ អមរិន្ទ ដានុត*

វ៉ាក់សាំង AstraZeneca ចំនួនប្រមាណ១លានត្រូវបានរដ្ឋាភិបាលជប៉ុនបានប្រកាសផ្តល់ជូនដល់កម្ពុជា ដែលជំនួយនេះធ្វើឡើងស្របតាមចំណងមិត្តភាពរវាង ជប៉ុននិងកម្ពុជា និងដោយផ្អែកលើស្ថានភាព កូវីដ១៩ នៅកម្ពុជានាពេលបច្ចុប្បន្ន។

លោក មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា បានឱ្យដឹងតាមរយៈសាររបស់លោកនៅថ្ងៃទី១៣ ខែកក្កដានេះថា វ៉ាក់សាំងដែលត្រូវបានផ្តល់អាជ្ញាបណ្ណផលិតក្នុងប្រទេសជប៉ុន នឹងត្រូវបានដឹកជញ្ជូនមកដល់រាជធានីភ្នំពេញក្នុងពេលដ៏ឆាប់ខាងមុខនេះនៅពេលដែលការរៀបចំភ័ស្តុភារដោយ COVAX Facility បានបញ្ចប់។

លោក មិកាមិ ម៉ាសាហ៊ីរ៉ូ បានលើកឡើងក្នុងសារនេះថា ៖ «ខ្ញុំសង្ឃឹមថា ជំនួយនេះនឹងជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ ក៏ដូចជាកាត់បន្ថយការព្រួយបារម្ភណ៍មួយចំនួនរបស់ប្រជាជនកម្ពុជា។ ក្នុងការប្រយុទ្ធប្រឆាំងនឹងកូវីដ១៩ដែលជាបញ្ហាពិភពលោកនេះ ជប៉ុននឹងបន្តសហការ និងធ្វើការរួមគ្នា ជាមួយកម្ពុជាដែលជាមិត្តដ៏សំខាន់របស់យើង»។

ប្រឈមមុខនឹងការរីករាលដាលនៃមេរោគឆ្លងថ្មីដែលពិភពលោកកំពុងជួបប្រទះនេះ ការចាក់វ៉ាក់សាំង និងការពង្រឹងប្រព័ន្ធសុខាភិបាលគឺជាកត្តាសំខាន់សម្រាប់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា។ មកទល់ពេល នេះ រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយស្មើនឹងសរុបប្រមាណ ច្រើនជាង៥០លានដុល្លារអាមេរិកដល់កម្ពុជាដែល រួមមានការផ្តល់បរិក្ខារពេទ្យ ការកែលម្អមន្ទីរពេទ្យ ការគាំទ្រដល់គម្រោងរបស់អង្គការអន្តរជាតិនានាសម្រាប់ វិធានការទប់ស្កាត់ការចម្លងជម្ងឺតាមព្រំដែន ក៏ដូចជាការផ្តល់បរិក្ខារសម្រាប់ដឹកជញ្ជូន និងរក្សាទុកវ៉ាក់សាំងឲ្យ បានត្រឹមត្រូវផងដែរ។

លោក មិកាមិ ម៉ាសាហ៊ីរ៉ូ បានបន្ថែមថា ៖ «យើងក៏បានផ្តល់ជាកម្ចីប្រមាណ ២២៧លានដុល្លារអាមេរិក ដែលត្រូវបានប្រើប្រាស់ក្នុង កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ប្រជាជនដែលរងផលប៉ះពាល់ដោយសារកូវីដ១៩ និងសម្រាប់ការពង្រឹងប្រព័ន្ធ សុខាភិបាល»។

យោងតាមរបាយការណ៍របស់ក្រសួងសុខាភិបាលបានឱ្យដឹងថា គិតត្រឹមថ្ងៃទី១២ ខែកក្កដា ប្រជាពលរដ្ឋជិត៥លាននាក់ ស្មើនឹងជិត៥០ភាគរយហើយដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩នៅទូទាំងប្រទេស៕

# លោក ប្រាក់ សុខុន ជំរុញវ៉ាក់សាំងឱ្យក្លាយជាទំនិញសាធារណៈសកល ក្នុងគោលបំណងពន្លឿនដំណើរការស្តារឡើងវិញក្រោយជំងឺរាតត្បាតនេះ

*អត្ថបទ៖ ផល សុផានិត*

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោក ប្រាក់ សុខុន បានលើកឡើងដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការជំរុញវ៉ាក់សាំងឱ្យក្លាយជាទំនិញ សាធារណៈសកល និងការចូលរួមរបស់រុស្ស៊ី ជាពិសេសក្នុងការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រទាំង៥ នៃក្របខ័ណ្ឌការស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន ក្នុងគោលបំណងពន្លឿនដំណើរការនៃការស្តារឡើងវិញក្រោយជំងឺរាតត្បាត និងបង្កើនភាពរឹងមាំ។




លោក ប្រាក់ សុខុន បានលើកឡើងដូចនេះ នៅក្នុងសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី (តាមប្រព័ន្ធវីដេអូ) នាថ្ងៃទី៦ ខែកក្កដានេះ ដែលលោកបានអញ្ជើញចូលរួមកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី២៥ នៃភាពជាដៃគូសន្ទនាអាស៊ាន-រុស្ស៊ី។

កិច្ចប្រជុំនេះ ត្រូវបានដឹកនាំដោយសហប្រធាន លោកស្រី Retno Marsudi រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ដែលជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនា អាស៊ាន-រុស្ស៊ី និងលោក Sergey Lavrov រដ្ឋមន្ត្រីការបរទេសនៃសហព័ន្ធរុស្ស៊ី។

កិច្ចប្រជុំបានផ្តល់នូវឱកាសដើម្បីពិនិត្យនូវសមិទ្ធផលនៃទំនាក់ទំនងអាស៊ាន-រុស្ស៊ី ដែលសម្រេចបានក្នុង រយៈពេល២៥ឆ្នាំកន្លងមក និងតាមដានលើលទ្ធផលនៃកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី ស្តីពីជំងឺកូវីដ-១៩ ដែលបានប្រព្រឹត្តទៅកាលពីឆ្នាំមុន។

ទាក់ទងនឹងកិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រដ្ឋមន្ត្រីអាស៊ានបានលើកទឹកចិត្តដល់ប្រទេសរុស្ស៊ីឱ្យគាំទ្រយន្តការឆ្លើយតបតំបន់ចំពោះជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីថែរក្សាឲ្យបាននូវវ៉ាក់សាំងពហុភាគីនិយម និងការទទួលបានវ៉ាក់សាំងប្រកបដោយសមធម៌។

លោករដ្ឋមន្ត្រី បានបង្ហាញការប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀត តាមរយៈការអនុវត្តផែនការ សកម្មភាព ឆ្នាំ២០២១-២០២៥ ប្រកបដោយប្រសិទ្ធភាព និងទន្ទឹងរង់ចាំកិច្ចប្រជុំកំពូលអាស៊ាន-រុស្ស៊ីលើកទី៤ នៅខែតុលា ឆ្នាំ២០២១ ដើម្បីរំលឹកខួបអនុស្សាវរីយ៍លើកទី២៥ នៃទំនាក់ទំនងសន្ទនា អាស៊ាន-រុស្ស៊ី។

នៅក្នុងកិច្ចប្រជុំនេះ លោក ប្រាក់ សុខុន បានគូសបញ្ជាក់អំពីចំណងមិត្តភាព យូរអង្វែងរវាងអាស៊ាន និងរុស្ស៊ី និងអំពីការគាំទ្រយ៉ាងរឹងមាំរបស់រុស្ស៊ីចំពោះមជ្ឈភាពអាស៊ាន ដែល បានឆ្លុះបញ្ចាំងតាមរយៈការចូលរួមយ៉ាងសកម្មរបស់រុស្ស៊ីនៅក្នុងយន្តការនានាដែលដឹកនាំដោយអាស៊ាន។

លោកបានលើកទឹកចិត្តដល់រុស្ស៊ីឱ្យបង្កើនការចូលរួមកម្រិតជាន់ខ្ពស់ និងកិច្ចសន្ទនាប្រកបដោយការស្ថាបនា នៅក្នុងក្របខ័ណ្ឌអាស៊ាន សំដៅលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងផលប្រយោជន៍ទៅវិញ ទៅមក។

ជាមួយគ្នានេះដែរ លោក ប្រាក់ សុខុន ក៏បានចែករំលែកជាមួយកិច្ចប្រជុំអំពីផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ២០២១-២០២៣ របស់ប្រទេសកម្ពុជា ដែលនឹងចាប់ផ្តើមក្នុង រយៈពេលខ្លីខាងមុខនេះ និងបានស្វាគមន៍ការកំណត់របស់ប្រទេសរុស្ស៊ី សម្រាប់ឆ្នាំ ២០២២-២០២៣ ជា «ឆ្នាំនៃវិទ្យាសាស្ត្របច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន-រុស្ស៊ី»។

កិច្ចប្រជុំនេះ បានស្វាគមន៍ការបញ្ចប់ការចរចារលើផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-រុស្ស៊ី ឆ្នាំ២០២១-២០២៥ ដែលដាក់ចេញនូវអាទិភាព និងវិធានការណ៍ ដើម្បីធ្វើឲ្យកាន់តែរឹងមាំនូវភាពជាដៃគូសន្ទនាអាស៊ាន-រុស្ស៊ី។ រដ្ឋមន្ត្រីអាស៊ាន និងរុស្ស៊ី នឹងមានជំនួប ម្តងទៀតនៅកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-រុស្ស៊ី នៅខែសីហា ឆ្នាំ២០២១ ដែលក្រោយកិច្ចប្រជុំ នោះ កម្ពុជានឹងទទួលភារកិច្ចបន្តពីប្រទេសឥណ្ឌូនេស៊ី ធ្វើជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូ សន្ទនាអាស៊ាន-រុស្ស៊ី សម្រាប់រយៈពេល៣ឆ្នាំបន្ទាប់(ចាប់ផ្តើមពីខែសីហា ឆ្នាំ២០២១ ដល់ខែសីហា ឆ្នាំ២០២៤)៕

# រដ្ឋបាលរាជធានីភ្នំពេញ អនុវត្តវិធានការ រុះរើផ្ទះបណ្តែតទឹក បាន៩៥ភាគរយ

*អត្ថបទ៖ ???????*

រដ្ឋបាលរាជធានីភ្នំពេញអនុវត្តវិធានការរុះរើ បែចិញ្ចឹមត្រី ផ្ទះបណ្តែតទឹកនិងសំណង់មិនរៀបរយនៅលើផ្ទៃទន្លេ សម្រេចបាន៩៥ភាគរយហើយ ដែលបានធ្វើឱ្យស្ថាន ភាពដងទន្លេក្នុងភូមិសាស្ត្ររាជធានីភ្នំពេញមានសោភ័ណភាពស្រស់ស្អាតនិងបរិស្ថានល្អ។

ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២៦របស់ក្រុមប្រឹក្សារាជធា នីភ្នំពេញក្រោមវត្តមានលោក ប៉ា សុជាតិវង្ស ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ នាព្រឹកថ្ងៃទី០៨ខែកក្កដាឆ្នាំ ២០២១នេះ នៅសាលារាជ ធានីភ្នំពេញ លោកមាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ បានមានប្រសាសន៍ឱ្យដឹងថា រាជធានីភ្នំពេញមានខណ្ឌចំនួន០៦ ដែលមានផ្ទះបណ្តែតទឹក បែត្រីនិងសំណង់មិនរៀបរយនៅតាមដងទន្លេ ដែលមានចំនួនរហូតដល់ ១៤៧២ទីតាំង ចែកចេញជា៤ប្រភេទ ក្នុងនោះមានប្រភេទជា បែត្រី សំណង់មិនរៀបរយ ដៃត្រី និងទូកនេសាទ ក្នុងចំនួននេះ មានបងប្អូនប្រជា ពលរដ្ឋបានស្ម័គ្រចិត្តរុះរើចេញមកលើគោក មានចំនួន ១២៤២ទីតាំង។

លោកបញ្ជាក់ថា ចំពោះទីតាំងចល័តដែលអាជ្ញាធរបានរៀបចំឲ្យពួកគាត់ចិញ្ចឹមត្រីជាបណ្តោះអាសន្នចំនួន២ទីតាំងផ្សេងគ្នា ក្នុងនោះទីតាំងទី១ នៅជាប់ព្រំប្រទល់រវាងស្រុកពញាឮនិងខណ្ឌព្រែក ព្នៅ មានចំនួន១៩៤ទីតាំង និងទីតាំងទី២ នៅជាប់និងស្រុកលើកដែកចំនួន១៩ ទីតាំង និងទីតាំងដែលបាន និងកំពុងរុះរើមានចំនួន១៧ ទីតាំង ។ ការងារខាងលើនេះ អាជ្ញាធររាជធានីភ្នំពេញ អនុវត្តបានជោគជ័យចំនួន ៩៥ភាគរយ គិតមកដល់ ពេលនេះ ។

លោកមាន ចាន់យ៉ាដា ក៏បានបញ្ជាក់ផងដែរថា ការអនុវត្តនូវវិធានការជុំវិញការរៀបចំសណ្តាប់ធ្នាប់របៀប រៀបរយទៅលើបែត្រី ផ្ទះទឹកនិងសំណង់មិនរៀបរយនៅលើផ្ទៃទឹក តាមដងទន្លេនៅរាជធានីភ្នំពេញទទួលបានជោគជ័យនេះ គឺដោយសារ អាជ្ញាធរមានវិធានការចំពោះ មុខល្អប្រសើរ សហការបានល្អជាមួយដៃគូពាក់ព័ន្ធ និងមានការគាំទ្រពីមហាជនយ៉ាងពេញទំហឹង។

លោក ប៉ា សុជាតិវង្ស នៅក្នុងឱកាសនោះ បានថ្លែងនូវការកោតសរសើរយ៉ាងខ្លាំង ចំពោះអាជ្ញាធររាជធានីភ្នំពេញក្រោមការដឹកនាំរបស់លោក ឃួង ស្រេង ជាអភិបាល ដែលអនុវត្តការរៀបចំសណ្តាប់ធ្នាប់លើផ្ទៃទឹកនេះបានយ៉ាងល្អប្រសើរនិងទទួលបានជោគជ័យ។

សូមជម្រាបជូនថា កាលពីថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២១ កន្លងមកនេះ ជាថ្ងៃដែល អាជ្ញាធរប្រើវិធានការរដ្ឋបាលចុះទៅរុះរើ បែចិញ្ចឹមត្រី ផ្ទះបណ្តែតទឹក ផ្ទះតូចៗ និង សំណង់មិនរៀបរយនៅលើផ្ទៃទន្លេ ដើម្បីបើកផ្លូវនាវាចរ កុំឲ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូហ្ស៊ី មានចរន្តទឹកហូរ គោករាក់ ពិសេសកុំឲ្យបន្តការប្រើប្រាស់ចំណីសម្រាប់ចិញ្ចឹមត្រី និងការបញ្ចេញកាកសំណល់ ការបន្ទោបង់ពាសវាលពាសកាលក្នុងទន្លេធ្វើឲ្យខូចខាតយ៉ាង ធ្ងន់ធ្ងរដល់ជីវៈចម្រុះក្នុងទឹក ខូចគុណភាពទឹក បំពុល បរិស្ថាន និងប៉ះពាល់ដល់សោភ័ណភាពរាជធានីភ្នំពេញ ព្រមទាំងប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ដែលបានប្រើប្រាស់ទឹកមិនស្អាតផងដែរ ហើយការងារនេះ បើគិតមក ដល់ពេលនេះអាជ្ញាធររាជធានីភ្នំពេញ អនុវត្តបានជោគជ័យ និងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន៕

# ក្រសួងសុខាភិបាល បានចេញសេចក្តីសម្រេចដាក់ឲ្យអនុវត្តគោលការណ៍ណែនាំប្រតិបត្តិ ស្តីពីការប្រើប្រាស់តេស្តរហ័សរកវីរុសកូវីដ-១៩

អត្ថបទ៖ ផល សុផានិត

ក្រសួងសុខាភិបាល បានចេញសេចក្តីណែនាំប្រតិបត្តិ លើការប្រើប្រាស់តេស្តរហ័សរកវីរ៉ុស កូវីដ១៩ សម្រាប់គ្រឹះស្ថានសុខាភិបាលឯកជន, ស្ថាប័ន និងអង្គភាពរដ្ឋមិនមែនសុខាភិបាល, បណ្តាច្រកទ្វារចេញ-ចូលប្រទេស, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងទៀត និងសម្រាប់បុគ្គលឯកជន។ នេះបើតាមសេចក្តីសម្រេចដែលបណ្តាញព័ត៌មាន នៅយប់ថ្ងៃទី០៧ ខែកក្កដានេះ។

ក្រសួងសុខាភិបាល បានបញ្ជាក់ថា គោលការណ៍ណែនាំប្រតិបត្តិស្តីពីការប្រើប្រាស់តេស្តរហ័សរកវីរុសកូវីដ១៩នេះ ត្រូវបានរៀបចំឡើងដោយផ្អែកតាមស្ថានភាព នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ និងវត្តមាននៃករណីនាំចូលមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) នៅក្នុងប្រទេសកម្ពុជា។

ដើម្បីរួមចំណែកនៅក្នុងការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត គោលការណ៍ណែនាំប្រតិបត្តិនេះ ក៏ត្រូវមានវិសាលភាពអនុវត្តផងដែរ ចំពោះការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមផ្ទះ ឬជាលក្ខណៈឯកជន។ គោលការណ៍ណែនាំប្រតិបត្តិនេះ នឹងត្រូវយកទៅប្រើប្រាស់ជំនួស «ឱ្យគោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់តេស្តរហ័ស រកអង់ទីហ្សែនកូវីដ-១៩ ក្នុងសេវាសុខាភិបាលឯកជនស្របច្បាប់»។

ដោយឡែក គោលការណ៍ណែនាំប្រតិបត្តិនេះ មិនមានវិសាលភាពអនុវត្ត ចំពោះគ្រឹះស្ថានសុខាភិបាលសាធារណៈ, សេវាថែទាំ និងព្យាបាលជំងឺកូវីដ-១៩ និងសេវាដទៃទៀតដែលពាក់ព័ន្ធនឹងការប្រយុទ្ធជំងឺកូវីដ-១៩ ដែលការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបន្តអនុលោមទៅ តាមគោលការណ៍ណែនាំ ដែលកំពុងនៅជាធរមាន៕

## បច្ចុប្បន្នភាពនៃ

# ការរីករាលដាល មេរោគកូវីដ ១៩

## នៅតំបន់អាស៊ាន ដែលមិនគួររំលង!





*អត្ថបទ៖ អមរិទ្ធ ដានុត*

អាស៊ានទាំងមូលកំពុងតែរងនូវសំពាធនៃការរីករាលដាលនិងការផ្ទុះការឆ្លងមេរោគកូវីដ១៩ យ៉ាងគំហុក នៅក្នុងអំឡុងខែ កក្កដា ឆ្នាំ២០២១ នេះ ដោយករណីឆ្លងសរុបនៅក្នុងតំបន់មានរហូតដល់ទៅ ៥,៦៦ លាននាក់ និងករណីឆ្លងប្រចាំថ្ងៃប្រមាណជា ៧៩.០០០ ករណី នៅទូទាំងតំបន់ ។

យោងទៅតាមរបាយការណ៍របស់អាស៊ានប៉ុស្តិ៍ បានឲ្យដឹងថា គិតត្រឹមម៉ោង ៧ ល្ងាចថ្ងៃទី ១៣ ខែ កក្កដា ប្រទេសឥណ្ឌូនេស៊ី ដែលជាប្រជាជាតិមានប្រជាជនច្រើនជាងគេនៅក្នុងតំបន់ គឺបានរងនូវបន្ទុះនៃការឆ្លង ក៏ច្រើនផងដែរ ដោយឡែក ស្ថានការណ៍នៅម៉ាឡេស៊ី ថៃ និង មីយ៉ាន់ម៉ា គឺកំពុងតែឈានដល់កម្រិតនៃការ ផ្ទុះមេរោគដ៏អាក្រក់បំផុត ដោយឡែកស្ថានការណ៍នៅវៀតណាម គឺហាក់កំពុងតែនៅមាត់ជ្រោះ នៃការផ្ទុះដ៏គំហុក ខណៈកំណត់ត្រានៃការរកឃើញករណីថ្មីប្រចាំថ្ងៃគឺនៅបន្តកើនឡើង ។

ស្ថានភាពនៃការឆ្លងមេរោគនេះនៅតែបន្តយ៉ាប់យ៉ឺននៅក្នុងប្រទេសឥណ្ឌូនេស៊ីខណៈដែលអាជ្ញាធរសុខាភិបាលនៅទីនោះបានរាយការណ៍ថាមានករណីថ្មីនៃរហូតដល់ទៅ ៤៧.៨៩៩ ករណី។ ចំនួនករណីដែលកំពុងតែផ្ទុកវិជ្ជមានមាន ចំនួនជាង ៤០០.០០០ នាក់ខណៈពេលដែលអ្នកស្លាប់ថ្មីនៅតែមាន លើសពី៨០០នៅក្នុងមួយថ្ងៃ ។ ដោយសារតែស្ថានភាពនេះ បញ្ហាកង្វះអុកស៊ីសែន ឧបករណ៍ផ្នែកវេជ្ជសាស្ត្រ កំពុងបង្កឲ្យប្រព័ន្ធសុខាភិបាលរបស់ឥណ្ឌូនេស៊ីនៅក្នុងស្ថានភាពដួលរលំ។

នៅប្រទេសម៉ាឡេស៊ីឯណោះវិញ ក្រសួងសុខាភិបាលបានរាយការណ៍អំពីករណីឆ្លងវីរុស ថ្មីប្រចាំថ្ងៃដល់ទៅ ១១.០៧៩ ជាហេតុបានធ្វើឲ្យប្រទេសនេះមានករណីវិជ្ជមានសកម្មជាង ៩៦.០០០ នាក់ រីឯករណី ស្លាប់វិញគឺ បន្តរាយការណ៍ប្រចាំថ្ងៃនៅក្នុងរង្វង់ ៣ ខ្ទង់ជាប្រចាំ។

នៅប្រទេសថៃវិញ ក្រសួងសុខាភិបាលសាធារណៈបាននិយាយនៅព្រឹកថ្ងៃអង្គារកន្លងទៅថា មានករណីស្លាប់ថ្មីចំនួន ៥៦ នាក់និងករណីថ្មីឆ្លងចំនួន ៨.៦៨៥ ករណី នៅក្នុងនោះប្រជាជនធម្មតាចំនួន ៨.៥៣៩ នាក់និងអ្នកទោសចំនួន ១៤៦ នាក់។ ឥឡូវនេះ ថៃកំពុងតែអនុវត្តវិធានការបិទខ្ទប់រាជធានី បាងកក និងខេត្តផ្សេងៗទៀតនៅភាគខាងត្បូង ចំនួន១០ ។

ទន្ទឹមនឹងនេះនៅក្នុងប្រទេសមីយ៉ាន់ម៉ាវិញ ស្ថានការណ៍ក៏កាន់តែអាក្រក់ទៅៗនៅពេលដែលអាជ្ញាធរសុខាភិបាលនៅទីនោះបានរាយការណ៍ថា មានករណីថ្មី ចំនួន ៥.០១៤ ករណី ។ កង្វះបុគ្គលិកសុខាភិបាល ការគ្រប់គ្រងដោយរបបយោធា និងការដាក់សំពាធពីបរទេសផងនោះ ការរីករាលដាលនៃមេរោគកូវីដ ១៩ នៅក្នុងប្រទេសនេះនឹងធ្វើឱ្យមានវិបត្តិសុខភាពនៅក្នុងប្រទេសនេះកាន់តែអាក្រក់ ។

សម្រាប់ស្ថានការណ៍នៅប្រទេសហ្វីលីពីនក៏មិនទាន់ប្រសើរណាស់ណានៅឡើយ ប្រទេសនេះនៅតែឈរនៅលេខរៀងទីពីរនៅក្នុងតំបន់ដែលមានករណីឆ្លងមេរោគច្រើនជាងគេ បន្ទាប់ពីឥណ្ឌូនេស៊ី ។ ក្រសួងសុខាភិបាលនៅ ប្រទេសនេះ បានរាយការណ៍ថាមានករណីថ្មី ៣.៦០៤ ថ្ងៃនេះ ខណៈពេលដែលការស្លាប់ថ្មីបានធ្លាក់ចុះដល់ ៧៧ នៅថ្ងៃនេះ។

ចំពោះស្ថានការណ៍នៃការឆ្លងមេរោគនៅប្រទេសវៀតណាមកំពុងមានការកើនឡើង ខណៈដែលករណីថ្មីកំពុងកើនឡើងជាលំដាប់នៅនារយៈពេលមួយសប្តាហ៍កន្លងមកនេះ។ អាជ្ញាធរសុខាភិបាលបានរាយការណ៍ថាមានករណីចំនួន ២.១៨៧ ករណី ខណៈដែលមួយថ្ងៃមុននេះមាន ១.៧២១ ករណី ដែលនាំឱ្យមានករណីសរុបនៅក្នុងប្រទេសឡើងដល់ជាង ៣២.០០០ ករណីជាមួយនឹងករណីសកម្មជាង ២៣.០០០ ករណីនាពេលបច្ចុប្បន្ន។ ប្រទេសវៀតណាមក៏បានកត់ត្រាការស្លាប់ថ្មីចំនួន ២ ករណី ។ នៅពេលនេះអាជ្ញាធរវៀតណាមកំពុងតែបិទខ្ទប់ទីក្រុងហូជីមិញ និង ពង្រីកដែនបិទខ្ទប់នេះ ជាបន្តបន្ទាប់ ប្រសិនបើការរកឃើញនៅតែបន្តកើតមាន ។

កម្ពុជាក៏មិនទាន់ធូរស្បើយប៉ុន្មានឡើយ ថ្វីបើយុទ្ធនាការនៃការចាក់វ៉ាក់សាំងបានសម្រេចបានជាង ៥០ ភាគរយហើយក៏ដោយ ។អាជ្ញាធរសុខាភិបាលក្នុងប្រទេសកម្ពុជាបានរាយការណ៍ថាមានករណីឆ្លងវីរុសថ្មីចំនួន ៨៣០ ករណីនៅថ្ងៃទី ១៣ ខែ កក្កដា និងករណីស្លាប់ថ្មី ២៨ នាក់ ។



សម្រាប់ប្រទេសឡាវវិញ តួរលេខ ហាក់មិនសូវធ្វើបច្ចុប្បន្នភាពទាន់ពេលនៅឡើយទេ ប៉ុន្តែ កំណើននៃ ករណីនាំចូលនិងការរកឃើញនៅក្នុងសហគមន៍ គឺនៅតែបន្តកើតមាន។ ករណីឆ្លងមេរោគសរុបនៅក្នុងប្រទេសនេះមានចំនួន សរុប ២.៨២៥ នាក់ ហើយ ។

ប្រទេសសិង្ហបូរីបានរាយការណ៍ថាមានករណីថ្មីចំនួន ២៦ ករណី ដែលករណីនេះ នៅទាបជាងគេ ហើយករណីបាត់បង់ជីវិតក៏ទាបផងដែរ ដោយឡែកប្រ៊ុយណេវិញ មកដល់ពេលនេះ មានករណីវិជ្ជមានទាំងអស់ត្រឹមតែ ២៧៧ ករណីប៉ុណ្ណោះ ហើយករណីកំពុងតែព្យាបាលគឺមាន១៨ករណី។

ការស្លាប់សរុបនៅទូទាំងអាស៊ីអាគ្នេយ៍ឥឡូវនេះមានចំនួន ១០៨.៥៩០ ជាមួយនឹងការស្លាប់ថ្មី ១.២៤១ ត្រូវបានកត់ត្រា។ នៅក្នុងចំណោមអ្នកដែលឆ្លងទាំងអស់ មកដល់ពេលនេះ មានពលរដ្ឋសរុបនៅក្នុងតំបន់ជា ៤,៨៣ លាននាក់បានជះសះស្បើយ ។

នៅក្នុងពេលនេះ រដ្ឋាភិបាលនៅក្នុងតំបន់អាស៊ានកំពុងតែជំរុញកិច្ចសហប្រតិបត្តិការណ៍ និង ការផ្លាស់ប្តូរ ព័ត៌មាន ជុំវិញការរីករាលដាលនៃមេរោគកូវីដ ១៩ ទោះបីជាវិធានការតំបន់ទាំងមូលហាក់អនុវត្តខុសៗគ្នា ទៅតាមស្ថានការណ៍នយោបាយ ភូមិសាស្ត្រ សេដ្ឋកិច្ច របស់ប្រទេសនីមួយៗក្តី ។ ប្រទេសខ្លះបានបិទខ្ទប់ ប្រទេសខ្លះនៅបានបើក ហើយកំពុងតែជំរុញការចាក់វ៉ាក់សាំង។ ដោយឡែកអ្វីដែលថ្មីនៅពេលនេះគឺផែនការនៃការចាក់វ៉ាក់សាំងនៅថៃ ខណៈដែលអាជ្ញាធរថៃ បានផ្តួចផ្តើមឲ្យមានការចាក់វ៉ាក់សាំងបញ្ចូលគ្នា រវាងវ៉ាក់សាំងស៊ីណូវ៉ាក់របស់ចិន និងវ៉ាក់សាំងអាស្ត្រាហ្សេនីកា ដែលកំពុងតែផលិតនៅក្នុងប្រទេសខ្លួន ខណៈដែលអ្នកជំនាញអង្គការសុខភាពពិភពលោកជំទាស់និងរិះគន់គំនិតផ្តួចផ្តើមនេះ។

# ធនាគារពិភពលោក អនុម័តកញ្ចប់ឥណទាន ២០០លានដុល្លារ ជួយកម្ពុជាក្នុងការស្តារសេដ្ឋកិច្ចឲ្យរើបឡើងវិញ

*អត្ថបទ៖ ផល សុផានិត*




ការខិតខំរបស់ ប្រទេសកម្ពុជា ដើម្បីប្រយុទ្ធទៅនឹងជំងឺកូវីដ១៩ ដែលកំពុងតែកើតមានឡើង និងការចាប់ផ្តើមឈានទៅស្តារសេដ្ឋកិច្ច ឲ្យងើបឡើងវិញ បានធ្វើឲ្យក្រុមប្រឹក្សានាយកប្រតិបត្តិនៃធនាគារពិភពលោក អនុម័តកញ្ចប់ឥណទាន មានតម្លៃទឹកប្រាក់ចំនួន២០០លានដុល្លារអាមេរិក របស់សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ (IDA) ។

តាមសេចក្តីប្រកាសព័ត៌មានរបស់ធនាគារពិភពលោក (World Bank) នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១នេះ បានបញ្ជាក់ថា គម្រោងនេះសម្រាប់គម្រោងរៀបចំគោលនយោបាយហិរញ្ញប្បទាន ដើម្បីជួយសង្គ្រោះការរើបឡើងវិញ និងការកសាងភាពធន់របស់កម្ពុជា (Cambodia Relief, Recovery and Resilience Development Policy Financing Project/DPF)។

គម្រោងនេះនឹងជួយកម្ពុជា ក្នុងការដោះស្រាយវិបត្តិកូវីដ១៩ តាមរយៈកិច្ចអន្តរាគមន៍សង្គ្រោះទាន់ពេលវេលា និងចំគោលដៅសម្រាប់ពលរដ្ឋងាយរងគ្រោះ, ការសម្រួលឲ្យសេដ្ឋកិច្ចរើបឡើងវិញ ដោយស្វាហាប់តាមរយៈការកែទម្រង់ជារចនាសម្ព័ន្ធ និងការកសាងភាពធន់សម្រាប់ទប់ទល់ ទៅនឹងស្ថានភាពអង្រួន ផ្នែកសេដ្ឋកិច្ចនាពេលអនាគត។

ប្រទេសកម្ពុជា កំពុងតែប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច និងសង្គមដែលមិនធ្លាប់មាន។ ជាលើកដំបូងហើយ ក្នុងរយៈពេល៣០ឆ្នាំ ដែលសេដ្ឋកិច្ចនៃប្រទេសនេះ នៅក្នុងឆ្នាំ២០២០ បានរួញទំហំអស់ ៣.១ភាគរយ ហើយពេលនេះ កម្ពុជាកំពុងស្ថិតនៅកណ្តាលស្ថានភាពដ៏អាក្រក់នៃការឆ្លងវីរុសកូវីដ១៩ ចាប់តាំងពីមានការផ្ទុះឡើងនៃការរាតត្បាតជំងឺនេះដំបូងមក។

វិស័យដែលរងផលប៉ះពាល់ខ្លាំងបំផុតរួមមាន ផ្នែកកាត់ដេរ ទេសចរណ៍ និងសំណង់ ហើយវិស័យទាំងនេះ សុទ្ធតែបានផ្តល់ការងារច្រើនជាង គេនៅកម្ពុជា ដែលវាបានបង្កើត បន្ថែមនូវបញ្ហាប្រឈមសម្រាប់ការស្តារសេដ្ឋកិច្ចឲ្យមាននិរន្តភាពឡើងវិញ។ ខណៈដែលវិធានទប់ស្កាត់បញ្ហាប្រឈមសំខាន់ៗបំផុត នៅមិនទាន់មាន ការរាតត្បាតជំងឺនេះ អាចនឹងបណ្តាលឲ្យភាពអត់ការងារធ្វើ និងភាពក្រីក្រកាន់តែកើនឡើងថែមទៀត ដែលក្នុងនោះ ពលរដ្ឋជិតមួយលាននាក់ត្រូវបានគេរំពឹងថា នឹងធ្លាក់ចុះទៅក្នុងភាពក្រីក្រវិញ។

ដើម្បីប្រយុទ្ធប្រឆាំងនឹងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញវិធានការឆ្លើយតបបន្ទាន់នានា ហើយបច្ចុប្បន្ន ក៏កំពុងតែរៀបចំផែនការសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ១៩ (Post-COVID-19 Economic Recovery Plan) ផងដែរ។ គម្រោង DPF នេះ នឹងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការទប់ស្កាត់ស្ថានការណ៍អាក្រក់ណាមួយ ដែលកើតចេញពីការរាតត្បាតរបស់ជំងឺនេះ ដោយជួយទ្រទ្រង់ដល់ចំណាត់ការនានា ក្នុងការផ្តល់ជំនួយសង្គ្រោះផ្នែកហិរញ្ញវត្ថុដល់គ្រួសារ និងក្រុមហ៊ុនដែលរងផលប៉ះពាល់។

ចំណាត់ការទាំងនោះ រួមមានការធ្វើកំណែទម្រង់ដើម្បីកែលម្អបរិយាកាសធ្វើធុរកិច្ច ព្រមទាំងវិធានការ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសមត្ថភាពរបស់ស្ថាប័នប្រមូលចំណូលរបស់រដ្ឋ។

លោកស្រី អ៊ីនហ្គ្លិណា ដូប្រាចា ប្រធានគ្រប់គ្រងរបស់ធនាគារពិភពលោកប្រចាំកម្ពុជា បានថ្លែងថា «ច្បាស់ណាស់ ប្រទេសកម្ពុជាពិតជាត្រូវការធនធាន ដែលអាចយកទៅបញ្ចេញឲ្យបានរហ័សសម្រាប់ទ្រទ្រង់ដល់កម្មវិធីគ្រប់ជ្រុងជ្រោយមួយរបស់រដ្ឋាភិបាល ដើម្បីការពារជនក្រីក្របំផុត ពីផលប៉ះទង្គិចរបស់វិបត្តិនេះ និងដើម្បីជួយដល់កិច្ចប្រឹងប្រែងស្តារសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសឲ្យងើបឡើងវិញ»។

គម្រោងនេះ ជាផ្នែកស្នូលមួយ នៃអន្តរាគមន៍ទូលំទូលាយមួយរបស់ធនាគារពិភពលោក ក្នុងការឆ្លើយតបទៅនឹងវិបត្តិកូវីដ១៩ ហើយក៏ជាផ្នែកមួយ នៃកញ្ចប់ប្រតិបត្តិការទ្រទ្រង់ថវិកាពីសំណាក់ដៃគូអភិវឌ្ឍន៍មួយចំនួនរបស់កម្ពុជា មានដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), សហភាពអឺរ៉ុប (EU), និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)៕

# USAID នឹងផ្តល់៣លានដុល្លារ លើគម្រោងស្តីពីការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធដឹកជញ្ជូនត្រជាក់





*អត្ថបទ៖ កក ស្រីនិ*

ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) គ្រោងផ្តល់នូវទឹកប្រាក់ចំនួន ៣លានដុល្លា លើការធ្វើឲ្យប្រសើរឡើង នូវប្រព័ន្ធដឹកជញ្ជូនត្រជាក់ (Cold Chain Logistic System) ដោយប្រើប្រព័ន្ធសូឡា ដើម្បីជួយដល់ការដាំដុះ និងការដឹកជញ្ជូនបន្លែ ផ្លែឈើ ត្រី សាច់មកកាន់ទីផ្សារឲ្យកាន់តែល្អប្រសើរ ធានាបានគុណភាព សុវត្ថិភាព និងតម្លៃ។

គម្រោងនេះធ្វើឡើងក្នុងជំនួបជម្រាបលារវាង លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោកស្រី វេនា រីតឌី (Veena Reddy) នាយកទីភ្នាក់ងារ USAID ប្រចាំនៅកម្ពុជា កាលពីចុងខែមិថុនាកន្លងមកនេះ។

នាឱកាសនេះ លោកស្រី វេនា រីតឌី បានរំលឹកនូវ ០៤ឆ្នាំត្រូវបានបញ្ចប់ បានបន្សល់ ទុកនូវអនុស្សាវរីយ៍ យ៉ាងច្រើនមិនអាចបំភ្លេចបាននៅលើទឹកដីអង្គរដ៏បវរ និងជាពិសេស សមិទ្ធផលសំខាន់ៗ ជាច្រើនតាមរយៈការអនុវត្តគម្រោងកម្មវិធីដែលទាក់ទងនឹងការអភិវឌ្ឍន៍វិស័យកសិកម្ម។

ប្រធានបញ្ចប់អណត្តិUSAID រូបនេះថ្លែងថា USAID គ្រោងនឹងជួយដល់កម្ពុជា ប្រាកដជាចូលរួមចំណែកធ្វើការ អភិវឌ្ឍប្រទេសមួយនេះឲ្យមានការរីកចម្រើនប្រកបដោយចីរភាព និរន្តរភាព និងវិបុលភាពនាពេលអនាគត។

លោក វេង សាខុន បានសម្តែងនូវការគាំទ្រ និងស្វាគមន៍ចំពោះគម្រោង ការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធដឹកជញ្ជូនត្រជាក់ (Cold Chain Logistic System) ដោយលោកបានបញ្ជាក់ថា ប្រព័ន្ធនេះនឹងជួយលើកកម្ពស់ប្រសិទ្ធភាពផលិតកម្មបន្លែ ផ្លែឈើ ត្រី សាច់ឲ្យកាន់តែល្អប្រសើរជាជំហានៗដោយផ្អែកទៅលើស្តង់ដារផលិត វេចខ្ចប់ ថែរក្សា ដឹកជញ្ជូន និងដាក់តាំងបង្ហាញពិតប្រាកដមួយ ដែលត្រូវបានទទួលស្គាល់ទាំងក្នុងតំបន់ និងអន្តរជាតិ។

លោកបានបញ្ជាក់បន្ថែមថា៖«នេះគឺជាគម្រោងដែលក្រសួងចង់បានដើម្បីលើកកម្ពស់គុណភាពសុវត្ថិភាពនៃផលិតផលកសិកម្ម បង្កើនផលិតកម្ម និងធានាគុណភាពកសិផល សុខមាលភាពសម្រាប់អ្នកបរិភោគ និងកំណើនតម្លៃបន្ថែម»៕

# ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថា ចំណូលពន្ធគយឆមាសទីមួយដើមឆ្នាំថយចុះជិត៩ភាគរយ

*អត្ថបទ៖ អរិយបុត្រ*

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអះអាងកាលពីថ្ងៃទី១៥ ខែ កក្កដា ថា ចំណូលពន្ធគយដែលប្រមូលបាននៅឆមាសទី១ ដើមឆ្នាំ២០២១ នេះ គឺមានចំនួន ៤.៦៩៥,៨ ប៊ីលានរៀល ស្មើ នឹង ១.១៥៩,៥ លានដុល្លា ថយចុះ ប្រមាណ ៨,៩%ធៀបនឹងឆមាសទី ១ ឆ្នាំ ២០២០ ។

ប្រភពដដែលបានអះអាងថា លទ្ធផលប្រមូលចំណូលរបស់អគ្គនាយករដ្ឋក្នុងឆមាសទី១ ឆ្នាំ២០២១នេះគឺសម្រេចបាន ៤៩%នៃផែនការឆ្នាំ ដែលកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ។

ប្រភពដដែលបានបន្តថា បើគិតតាមប្រភេទពន្ធនិងអាករ ឃើញថា អាករលើតម្លៃបន្ថែមមានចំនួន ១.៧៧៥,០១ប៊ីលានរៀល ត្រូវជាប្រមាណ ៣៧,៨%នៃចំណូលសរុប, អាករពិសេសមានចំនួន ១.៧៦៥,០២ ប៊ីលានរៀល ត្រូវជា ៣៧,៦% នៃចំណូលសរុប, ពន្ធគយមាន ៨៤៧,៦៣ ប៊ីលានរៀល ត្រូវជា ១៨,១%នៃចំណូលសរុប) អាករបន្ថែមលើ ផលិតផលប្រេងមាន ២១៤ ប៊ីលានរៀលត្រូវជា ៤, ៥% នៃចំណូលសរុប , និងអាករនាំចេញនិងកម្រៃផ្សេងៗ មាន ៩៤,១៣ ប៊ីលានរៀល ត្រូវជា ២% នៃចំណូលសរុប)។

ប្រភពដដែលបានបន្តថា បើគិតតាមក្រុមទំនិញវិញ ចំណូលពីយានយន្ត និងគ្រឿងចក្រមានចំនួន១.៩៨៥,៥ ប៊ីលានរៀល គ្របដណ្តប់ ៤២,៣% នៃចំណូលសរុប, ទំនិញចម្រុះមានចំនួន ១.៣១៦, ៣ ប៊ីលានរៀល ត្រូវជា ២៨% នៃចំណូលសរុប, ផលិតផលតេលសិលាមានចំនួន១.១០១, ៩ ប៊ីលានរៀល ស្មើនឹង ២៣, ៥% នៃចំណូលសរុប និង សម្ភារសំណង់និងកម្រៃផ្សេងៗ មានចំនួន ២៩២,២ ប៊ីលានរៀល ស្មើនឹង ៦,២% នៃចំណូលសរុប ។





ប្រភពដដែលបានបន្តថា បើពិនិត្យមើលតួលេខនៃទំហំពាណិជ្ជកម្មអន្តរជាតិក្នុងឆមាសទី១ ឆ្នាំ២០២១ ធៀបនឹងឆមាសទី១ ២០២០ គឺថា ការនាំចេញផលិតផលកាត់ដេរមានចំនួន ៤.៧២១,៤ លានដុល្លារអាមេរិក កើនឡើងប្រមាណ ៤០,១ លានដុល្លារអាមេរិក ស្មើនឹង ០,៩%, ការនាំចេញផលិតផលវិនិយោគមិនមែនកាត់ដេរ ដូចជា កង់ គ្រឿងបំណែកអេឡិចត្រូនិក បង្អំ ខ្សែភ្លើង គ្រឿងបន្លាស់រថយន្ត អំពូលលម្អ កុងផ្លាកេ និងផលិតផលឧស្សាហកម្មផ្សេងៗទៀត មានចំនួន ១.៨៩៩,៧ លានដុល្លារអាមេរិក កើនឡើងប្រមាណ ៦៣២,៥ លានដុល្លារអាមេរិក ស្មើនឹង ៤៩,៩% ។

ប្រភពដដែលបានបញ្ជាក់ថា៖ «កំណើនល្អប្រសើរនៃការនាំចេញផលិតផលវិនិយោគមិនមែនកាត់ដេរបាន ឆ្លុះបញ្ចាំងពីលទ្ធផលនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មវិស័យឧស្សាហកម្មនៅកម្ពុជា» ។

ប្រភពដដែលបានបន្តថា ការនាំចេញកសិផលមានចំនួន ១.៥៨០,៦ លានដុល្លារអាមេរិក កើនឡើងប្រមាណ ៦១៧,៦ លានដុល្លារអាមេរិក ឬ ៦៤.១៣% ក្នុងនោះរួមមាន: ស្រូវនាំចេញមានចំនួន ១,៦៩ លានតោន មានតម្លៃ ៤២៥,១ លានដុល្លារអាមេរិក កើនឡើងប្រមាណ ១.០១៩,៧ ពាន់តោន ឬ១៥១,៧% ឬស្មើនឹងប្រមាណជា ២៨៥,១ លានដុល្លារអាមេរិក (២០៣,៥%), ការនាំចេញអង្ករសម្រេចបាន ២៩១,១ ពាន់តោន មានតម្លៃ ២០៤,២ លានដុល្លារអាមេរិក ថយចុះប្រមាណ ៧៨,១ ពាន់តោន (២១,២%) ឬប្រមាណ ៦០,៥ លានដុល្លារអាមេរិក (២២.៩%), កៅស៊ូនាំចេញមានចំនួន ១០២,៨ ពាន់តោន មានតម្លៃ ១៥៧,៦ លានដុល្លារអាមេរិក កើនឡើងប្រមាណ ៤៥,៦ ពាន់តោន (៧៩,៧%) ឬប្រមាណ៨៧ លានដុល្លារអាមេរិក (១២៣,២%) និងកសិផលផ្សេងទៀតមានចំនួន ៣.៥៩២,៧ ពាន់តោន មានតម្លៃ ៧៩៣,៧ លានដុល្លារអាមេរិក កើនឡើងប្រមាណ ១.១៤១,៩ ពាន់តោន(៤៦.%) ឬប្រមាណ ៣០៦ លានដុល្លារអាមេរិក (៦២,៨%)។

ទន្ទឹមនឹងការងារប្រមូលចំណូលនេះ គយក៏សម្រេចបានលទ្ធផលល្អលើការងារសំខាន់ៗមួយចំនួន ទៀត ដែលមានចែងក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២១ ដូចជា: ការអនុវត្តនូវគោលនយោបាយ និង វិធានការនានារបស់រាជរដ្ឋាភិបាលក្នុងការទ្រទ្រង់និងស្តារសេដ្ឋកិច្ចដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩, ការបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ និងពង្រឹងអនុលោមភាព, ការបន្តលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មនិងកែលម្អបរិយាកាសវិនិយោគតាមរយ:ការធ្វើសាមញ្ញកម្មនីតិវិធីគយ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការងារគយ, និង ការចូលរួមសកម្មភាពសង្គមនានា និងអនុវត្តវិធានការសុខាភិបាលដើម្បីរួម ចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាដើម ។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ បានណែនាំបន្ថែមដល់មន្ត្រីក្រោមឱវាទ អគរ ទាំងអស់ឱ្យយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងការកៀរគរចំណូលប្រកបដោយភាពសកម្ម បុរេសកម្ម និងវៃឆ្លាត ព្រមទាំងប្រើប្រាស់ឱ្យអស់សក្តានុ ពល បញ្ញាស្មារតី ដើម្បីប្រមូលចំណូលឲ្យបានគ្រប់និងលើសផែនការ ហើយទន្ទឹមនឹងនោះត្រូវរក្សាបាននូវនិរន្តរភាព ការងារ និង ប្រកាន់នូវវិធានការអនាម័យបទាំងក្នុងការងារ និងការរស់នៅ ដើម្បីធានាបានសុវត្ថិភាព ដោយអនុវត្ត ឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល ៣ កុំ និង ៣ ការពារ ។ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូក៏បានណែនាំដល់ថ្នាក់ ដឹកនាំ អគរ ឱ្យបន្តចូលរួមក្នុងការងារសង្គមក្នុងគ្រាដ៏លំបាកនេះ តាមរយ:ការបន្តអនុវត្តយុទ្ធនាការមនុស្សធម៌ ចុះជួយសម្រួលការលំបាករបស់ជនងាយរងគ្រោះ ដូចជា កុមារកំព្រា និងក្រុមជនទីទាល់ក្រ ជាដើម៕

# កម្ពុជាប្រកាសផ្អាកការធ្វើដំណើរឆ្លងព្រំដែនជាមួយនឹងវៀតណាមមួយខែ

*អត្ថបទ៖ អរិយបុត្រ*

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានឱ្យដឹងថា ការធ្វើដំណើឆ្លងព្រំដែនរវាងកម្ពុជានិងវៀតណាមនឹងត្រូវផ្អាកជាបណ្តោះអាសន្នរយ:ពេលមួយខែដោយចាប់ផ្តើមពីថ្ងៃទី ១៨ ខែ កក្កដា តទៅ។

លោក អ៊ុច បូរិទ្ធិ រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានសរសេរលិខិតផ្លូវការមួយដើម្បីជូនដំណឹងដល់ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម កាលពីថ្ងៃទី១៣ ខែ កក្កដា ។

លោកបានបញ្ជាក់ថា ដោយមានការយល់ព្រមពីសម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី ១២ ខែ កក្កដា រាជរដ្ឋាភិបាលបានសម្រេចផ្អាកជាបណ្តោះអាសន្ននូវការធ្វើដំណើរចេញ និងចូលព្រំដែនកម្ពុជា - វៀតណាមរបស់កម្មករជំនាញ អ្នកបច្ចេកទេស និយោជិករបស់ក្រុមហ៊ុនវៀតណាមអស់រយ:ពេលមួយខែគិតចាប់ពីថ្ងៃទី ១៨ ខែកក្កដា តទៅ ដើម្បីបញ្ឈប់ការរីករាលដាលនៃមេរោគកូវីដ ១៩ ។

លោកបានសរសេរបញ្ជាក់ថា ការហាមឃាត់ជាបណ្តោះអាសន្ននេះមិនរាប់បញ្ចូលអ្នកជំងឺដែលត្រូវការការព្យាបាលនៅប្រទេសវៀតណាម អ្នកការទូត មន្ត្រីរាជការ សិស្សនិស្សិត ឬសិក្ខាកាមដែលបានអញ្ជើញដោយរដ្ឋាភិបាលនៃប្រទេសទាំងពីរ ឬមានករណីពិសេសមួយចំនួនពីរាជរដ្ឋាភិបាល។

ប្រភពដដែលបានបន្តថា និយោជិកឬកម្មករជំនាញរបស់ក្រុមហ៊ុនវៀតណាមដែលបានចូលមកប្រទេសកម្ពុជាទាំងអ្នកដែលបានធ្វើចត្តាឡីស័ក្ករួច និង កំពុងធ្វើ មិនត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់ទៅប្រទេសវៀតណាមវិញក្នុងអំឡុងពេលផ្អាកនោះទេ។

នៅក្នុងពេលជាមួយគ្នានេះក្រសួងការបរទេសក៏បានស្នើឱ្យឯកអគ្គរាជទូតកម្ពុជាប្រចាំនៅវៀតណាម សហការជាមួយអាជ្ញាធរវៀតណាមក្នុងការស្នើសុំអាជ្ញាធរនៃប្រទេសទាំងពីរឱ្យជួយសម្រួលដល់ដំណើរការនៃការដឹកជញ្ជូន នាំចេញ និងនាំចូលទំនិញក្នុងវិធានការតឹងរឹងស្របតាមបទបញ្ញត្តិសុខភាពរបស់ប្រទេសទាំងពីរ។

ទាក់ទងទៅនឹងការផ្អាកការធ្វើដំណើរជាបណ្តោះអាសន្ននេះកាលពីថ្ងៃទី ១២ លោក វេង សាខុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទក៏បានអំពាវនាវដល់ក្រុមហ៊ុនវៀតណាមទាំងអស់នៅក្នុងវិស័យកសិកម្ម ឱ្យផ្អាកការធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជានិងវៀតណាមផងដែរ។

លោកបានសរសេរនៅក្នុងលិខិតមួយ ដោយបញ្ជាក់ថា ដើម្បីរួមដៃគ្នាឲ្យកាន់តែប្រសើរឡើងដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺរាតត្បាតទី ១៩ ក្រសួងបានស្នើសុំប្រធានឬតំណាងក្រុមហ៊ុនវៀតណាមដែលកំពុងវិនិយោគលើដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជាដើម្បីផ្អាកការធ្វើដំណើររបស់កម្មករវៀតណាមទាំងអស់ឆ្លងកាត់ព្រំដែន ជាបណ្តោះអាសន្ន ។

លោក រស់ ផារិទ្ធ អភិបាលរងខេត្តស្វាយរៀង បាន មានប្រសាសន៍ប្រាប់អ្នកសារព័ត៌មានថា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងខេត្តជាពិសេសតំបន់ព្រំដែនជាមួយប្រទេសវៀតណាមបាននិងកំពុងរឹតបន្តឹងវិធានការសុវត្ថិភាពដើម្បីទប់ស្កាត់ការផ្ទុះឡើងនៃវីរុសនេះ។

លោកបានថ្លែងថា វិធានការបង្ការនិងការពារមេរោគកូវីដ ១៩ ត្រូវបានរឹតបន្តឹងនៅតាមច្រកព្រំដែនទាំងអស់ជាមួយប្រទេសវៀតណាមក្នុងខេត្តស្វាយរៀង។

លោកបានបញ្ជាក់ថា ច្រកទ្វារព្រំដែនទាំង ៨ នៅក្នុងខេត្តស្វាយរៀង ជាមួយប្រទេសវៀតណាម ក្នុងនោះមានច្រកព្រំដែនអន្តរជាតិចំនួន ២ គឺសុទ្ធតែបានរៀបចំពង្រឹងតាមការសម្រេចរបស់រាជរដ្ឋាភិបាល ។

គួររំលឹកថា កាលពីឆ្នាំមុនសហគ្រាសវៀតណាមបានវិនិយោគទឹកប្រាក់ប្រមាណ ២,៧ ពាន់លានដុល្លារនៅកម្ពុជាដែលឈរនៅលំដាប់ទី ៣ បន្ទាប់ពីប្រទេសឡាវដែលទទួលបានទុនវិនិយោគច្រើនបំផុតពីសហគ្រាសវៀតណាម ហើយ ក្នុងរយ:ពេល ៤ ខែដំបូងនៃឆ្នាំ ២០២១ ប្រទេសកម្ពុជាបានទទួលគម្រោងវិនិយោគចំនួន ៨៩,១ លានដុល្លារអាមេរិកបន្ថែមទៀតពីសហគ្រាសវៀតណាម៕

# អន្តរកាលវិបត្តិកូវីដ១៩៖ ពលករចំណាកស្រុកកម្ពុជាជាង ២០០,០០០នាក់ វិលត្រឡប់មកផ្ទះវិញ ក្នុងនោះជាង៤០ភាគរយជាស្ត្រី

*អត្ថបទ៖ ផល សុផានិត*

ស្ថិតក្នុងវិបត្តិជំងឺសកល ឬវិបត្តិជំងឺកូវីដ១៩តាំងពីចាប់ផ្តើមកាលពីអំឡុងចុងឆ្នាំ២០១៩មកដល់បច្ចុប្បន្ននេះ ពលករចំណាកស្រុកកម្ពុជាជាង២០០,០០០ នាក់ បានវិលត្រឡប់ពីប្រទេសជិតខាងមកកម្ពុជាវិញ ក្នុងនោះមានចំនួន៤៣ ភាគរយជាស្ត្រី។

យោងតាមរបាយការណ៍របស់ អង្គការសហប្រជាជាតិ (UN) បានឱ្យដឹងថា ការបាត់បង់ការងារ ការរឹតត្បិតសេដ្ឋកិច្ច និងការបិទខ្ទប់នៅប្រទេសម្ចាស់ផ្ទះ គឺជាបុព្វហេតុចម្បង បង្ខំឱ្យពលករចំណាកស្រុកវិលត្រឡប់មកប្រទេសកំណើតរបស់ពួកគេវិញ។



របាយការណ៍បានបង្ហាញថាជិត ៣០% នៃគ្រួសារពលករចំណាកស្រុក ដែលវិលត្រឡប់មកវិញមិនមានប្រាក់ចំណូលអ្វីទាំងអស់ ហើយច្រើនជាង ៥០% នៃពលករចំណាកស្រុក ដែលវិលត្រឡប់មកវិញ គឺសុទ្ធតែមានបំណុល។ ស្ត្រីដែលបានវិលត្រឡប់មកធ្វើចំណាកស្រុកវិញ គ្មានប្រាក់ចំណូល ហើយប្រឈមនឹងការលំបាក ក្នុងការស្វែងរកការងារធ្វើថ្មី។

បើនិយាយពីការទទួលបានជំនួយសង្គម និងសេវាសុខភាពចាំបាច់មានតែ ២៥% នៃជនចំណាកស្រុកដែលបានវិលត្រឡប់វិញ មានអត្តសញ្ញាណប័ណ្ណ និងជាង៤៩% មានបញ្ហាក្នុងការទទួលបានសេវាថែទាំសុខភាព ដោយសារខ្វះខាតប្រាក់។

អង្គការសហប្រជាជាតិ សហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល ដើម្បីជួយដល់ពលករចំណាកស្រុក ដែលវិលត្រឡប់ និងការពារសិទ្ធិរបស់ពួកគេ។ អង្គការសហប្រជាជាតិ ផ្តល់អាទិភាព ដល់ការផ្តល់ជំនួយដោយផ្ទាល់ ដល់ពលករចំណាកស្រុក នៅច្រកព្រំដែន និងកន្លែងដាច់ឆ្ងាយនិងកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម ទៅលើអ្នកដែលងាយរងគ្រោះបំផុត និងការពារការរីករាលដាលនៃមេរោគកូវីដ១៩ នៅក្នុងសហគមន៍នានា។

តាមរយៈមជ្ឈមណ្ឌលធនធានពលករចំណាកស្រុកដែលគាំទ្រដោយ អង្គការសហប្រជាជាតិ កំពុងផ្តល់ការប្រឹក្សាការ ផ្គត់ផ្គង់ស្បៀងអាហារ ការដឹកជញ្ជូន ការបណ្តុះបណ្តាលជំនាញ ការដោះស្រាយវិវាទ និងឱកាសការងារ សម្រាប់ពលករចំណាកស្រុកដែលនឹងចេញទៅបរទេសវិញ។

ដើម្បីជួយសំរួល ដល់ការការពារ និងការគ្រប់គ្រង អង្គការសហប្រជាជាតិ បានផ្តល់ជូនពលករចំណាកស្រុក ដែលវិលត្រឡប់មកកម្ពុជាជាង ១២៥,០០០ នាក់នូវសេវាកម្មទឹកស្អាត និងអនាម័យ ដូចជាការផ្គត់ផ្គង់សាប៊ូ និងសំភារៈសំអាត ជាប្រចាំ។ បង្កើតស្ថានីយ៍លាងចានចល័ត និងជួសជុលបង្គន់អនាម័យនៅចំណុចច្រកព្រំដែន និងកន្លែងទីសំចតជាក់លាក់។

ពលករចំណាកស្រុកជាង ១៦២.០០០ នាក់ដែលវិលត្រឡប់មកដល់ចំណុចច្រកព្រំដែនប្រទេសកម្ពុជា និងអ្នកដែលត្រូវបានបញ្ជូន ទៅឱ្យធ្វើចត្តាឡីស័ក បានទទួលព័ត៌មាន ស្តីពីការការពារសុខភាព និងសេវាកម្មសង្គមទប់ទល់និងជំងឺកូវីដ១៩ ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ និងអង្គការដៃគូ។

ការផ្តល់ជំនួយ ការការពារសុខភាព និងជំនាញ

អង្គការសហប្រជាជាតិ សហការជាមួយដៃគូ បានផ្តល់ជំនួយ ដោយផ្ទាល់ជូនដល់ពលករចំនួន ១៣១.០០០ នាក់ ដែលមកដល់ចំណុចច្រកព្រំដែន ហើយអ្នកដែលត្រូវបញ្ជូនទៅកន្លែងធ្វើចត្តាឡីស័ក បានទទួលជំនួយស្បៀងអាហារបន្ទាន់។ ពលករចំណាកស្រុក ជាង ១៦.០០០ នាក់ដែលត្រូវបានធ្វើចត្តាឡីស័ក បានទទួលសម្ភារៈអនាម័យ ដែលរួមមាន ទាំងការគេង និងសម្ភារៈអនាម័យផ្ទាល់ខ្លួន។

ក្រសួងសុខាភិបាល អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដៃគូអង្គការសហប្រជាជាតិ បានគាំទ្រដល់ពលករដែលងាយរងគ្រោះ (រួមមាន កុមារ ស្ត្រី គ្រួសារស្ត្រី និងអ្នកផ្ទុកមេរោគអេដស៍) ក្នុងការទទួលបានសេវាសុខភាព និងសង្គមតាមរយៈការបញ្ជូនទៅក្នុងសហគមន៍របស់ពួកគេ ។រួមទាំងការសម្រួលដល់ការចូលទៅកាន់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ (ID Poor) និងព័ត៌មានអំពី ឱកាសការងារនិងការបណ្តុះបណ្តាល។

នៅខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប កំពង់ចាម ព្រៃវែង និងកំពត អង្គការសហប្រជាជាតិបានធ្វើការដើម្បីពង្រឹងជីវភាព និងគាំទ្រដល់ពលករ ដែលបានវិលត្រឡប់មកវិញ ចំនួនជាង ៧០០ នាក់ជាមួយ នឹងជំនួយជាសាច់ប្រាក់ ដើម្បីបង្កើតសកម្មភាព មុខរបរ និងបង្កើតប្រាក់ចំណូលឡើងវិញ។

ការដោះស្រាយផលប៉ះពាល់ លើសុខភាពផ្លូវចិត្ត គឺជាផ្នែកដ៏សំខាន់មួយនៃការឆ្លើយតបរបស់អង្គការសហប្រជាជាតិលើកម្មវិធីទប់ស្កាត់ជំងឺកូវីដ១។ ដើម្បីបំពេញកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសុខាភិបាល អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ បានបណ្តុះបណ្តាលអ្នកជំនាញ មន្ត្រីរាជ និងបុគ្គលិកសេវាសង្គមចំនួនជាង ៨០០ នាក់លើការផ្តល់ប្រឹក្សាផ្នែកចិត្តសាស្ត្រ ដល់កុមារ ស្ត្រី រួមទាំងពលករ ជាស្ត្រីក្នុងការដាក់ឱ្យធ្វើចត្តាឡីស័ក។

កុមារ ឪពុកម្តាយ និងអ្នកថែទាំជាង ១៧៥.០០០ នាក់ត្រូវបានទទួលបាន នូវសកម្មភាព លើកកម្ពស់ការយល់ដឹង និងការពិគ្រោះយោបល់លើសុខភាពផ្លូវចិត្ត និងការគាំទ្រផ្លូវចិត្ត។ លើសពីនេះទៀត











អង្គការសហប្រជាជាតិបានផលិតខ្សែវីដេអូគំនូរជីវចលចំនួន ៣ ដែលផ្តោតលើការវិលត្រឡប់របស់ពលករចំណាកស្រុក ដោយផ្តោតលើសុខភាពផ្លូវចិត្ត ឱកាសការងារ និងការធ្វើចំណាកស្រុកដែលបានទៅដល់ជិត ៥០ ម៉ឺននាក់។

**ការរីករាលដាលនៃជំងឺកូវីដ១៩ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ត្រី រួមទាំងពលករចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា**

ការឆ្លើយតបរបស់អង្គការសហប្រជាជាតិបានផ្តល់អាទិភាពដល់សេវាកម្ម បង្ការអំពើហឹង្សាប្រឆាំងនឹងភេទ (យេនឌ័រ) ក្នុងអំឡុងពេលមានជំងឺរាតត្បាតរួមទាំង សេវាបញ្ជូន និងទីជំរកប្រកបដោយសុវត្ថិភាព ការប្រឹក្សាយោបល់ និងយុទ្ធនាការព័ត៌មានសាធារណៈ ដែលកំពុងបន្តមានគោលបំណងផ្លាស់ប្តូរឥរិយាបថ និងការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីចំណាកស្រុក។

ពលករចំណាកស្រុកងាយរងគ្រោះជាង ៣.៦០០ នាក់បានទទួលសម្ភារៈ អនាម័យនៅតាមកន្លែងធ្វើចត្តាឡីស័ក និងនៅតំបន់ដែលពលករទាំងនោះបានចូលមកដល់។ ដោយមានការគាំទ្រពី អង្គការសហប្រជាជាតិ បុគ្គលិកសង្គមកិច្ច របស់រដ្ឋាភិបាលចំនួន ៣៥ នាក់ត្រូវបានដាក់ពង្រាយ ជាពិសេស ដើម្បីឃ្លាំមើលស្ថានភាពកុមារដោយផ្តោតលើកុមារនៃពលករដែលវិលត្រឡប់មកវិញផ្តល់នូវការគ្រប់គ្រងករណី និងសម្របសម្រួលការបញ្ជូន។

ស្ត្រីចំណាកស្រុកជាង ៥.០០០ នាក់ដែលបានវិលត្រឡប់មកវិញ ត្រូវបានផ្តល់ការគាំទ្រថែទាំមាតាព័ត៌មាននិងការគាំទ្រផ្នែក យេនឌ័រ។

អង្គការសហប្រជាជាតិ បន្តគាំទ្រដល់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គស្នងការដ្ឋាននគរបាលជាតិដើម្បីអនុម័តវិធីសាស្ត្រអនុវត្ត តាមដានសុខភាព ដើម្បីគ្រប់គ្រង នៅតាមបន្ទាត់ព្រំដែន ដើម្បីកាត់បន្ថយហានិភ័យដែលជាប់ទាក់ទងនឹងជំងឺកូវីដ១។ មន្ត្រីជួរមុខជាង ៧៥០ នាក់នៅប៉ុស្តិ៍ត្រួតពិនិត្យសំខាន់ៗនៅព្រំដែនកម្ពុជា-ថៃបានទទួលការបណ្តុះបណ្តាលពីការការពារជំងឺកូវីដ១៩ និងផ្តល់នូវឧបករណ៍ការពារផ្ទាល់ខ្លួនពីវីរុសកូវីដ១។ លើសពីនេះទៀត អង្គការសហប្រជាជាតិ គាំទ្រដល់ កិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការជួញដូរមនុស្សតាមរយៈវិធានការនានា ដូចជាការសង្ខេបព័ត៌មានអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការបណ្តុះបណ្តាល សមត្ថភាព ដល់មន្ត្រីរដ្ឋាភិបាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលសង្ស័យពីការជួញដូរមនុស្ស ការទទួលបានឱកាសចិញ្ចឹមជីវិត និងកម្មវិធីបណ្តុះបណ្តាលជំនាញបន្តសម្រាប់ជនអន្តោប្រវេសន៍នាពេលអនាគត។

កម្មករ ជនអន្តោប្រវេសន៍ ចំនួនជាង ៧៥.០០០ នាក់បានទទួលព័ត៌មាន អំពីការធ្វើចំណាកស្រុក ពលកម្ម ទៀងទាត់ ការទទួលបានសេវាកម្មគាំទ្រសម្រាប់ពលករ និងការការពារខ្លួនពីវីរ៉ុសកូវីដ១៩ តាមរយៈមជ្ឈមណ្ឌលធនធាន ជនចំណាកស្រុកនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបន្តលើកកម្ពស់ការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយ សុវត្ថិភាពដល់ជនចំណាកស្រុកយ៉ាងតិច ៧.០០០ នាក់និងអ្នកដែលចង់ធ្វើចំណាកស្រុក នៅតាមខេត្តសំខាន់ៗ ដូចជាខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម ព្រៃវែង និងកំពត។

អង្គការសហប្រជាជាតិ លើកទឹកចិត្ត ឱ្យអាជ្ញាធរ ការពារនិងផ្តល់សិទ្ធិ ដល់ពលករ ដែលវិលត្រឡប់មកស្រុកវិញ ដើម្បីជួយពួកគេឱ្យជៀសផុត ពីផលប៉ះពាល់ជាបន្ទាន់ និងយូរអង្វែងនៃជំងឺរាតត្បាតសកល ឬកូវីដ១៩ នេះរួមបញ្ចូលទាំងការការពារសិទ្ធិមនុស្ស ជាមូលដ្ឋាន និងសិទ្ធិការងាររបស់ពលករវិលត្រឡប់និងក្រុមគ្រួសាររបស់ពួកគេស្របតាមកាតព្វកិច្ច សិទ្ធិមនុស្សអន្តរជាតិ ដូចជាសិទ្ធិទទួលបាន ការគាំពារសង្គមការរស់នៅ និងការថែទាំសុខភាព។

អង្គការសហប្រជាជាតិ ក៏បានអំពាវនាវ ដល់អាជ្ញាធរ ដើម្បីធានាថាការកំណត់ អត្តសញ្ញាណជនក្រីក្រ ត្រូវបានផ្តល់ជូនដល់ពលករ ចំណាកស្រុកដែលបំពេញតាមលក្ខណៈវិនិច្ឆ័យ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងជំនួយបន្ថែមត្រូវបានផ្តល់ សម្រាប់ការទទួលបានការងារ ឬឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភា ពនៅក្នុងសហគមន៍៕

# កម្ពុជាប្តេជ្ញារួមកម្លាំងជាមួយអាស៊ាន ដើម្បីនាំភូមាឱ្យវិលទៅរកភាពប្រក្រតីឡើងវិញ




*អត្ថបទ៖ ផល សុផានិត*

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីលទ្ធផលនៃកិច្ចសន្ទនាតាមទូរសព្ទរវាងលោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិប ត្តិការអន្តរជាតិ និងលោកស្រី ម៉ារីស ផេន រដ្ឋមន្ត្រីការបរទេស និងជារដ្ឋមន្ត្រីកិច្ចការនារីអូស្ត្រាលី ចេញនៅថ្ងៃទី០៧ ខែកក្កដា បានឱ្យដឹងថា នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ លោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានពិភាក្សាការងារតាមទូរសព្ទជាមួយលោកស្រី ម៉ារីស ផេន រដ្ឋមន្ត្រីការបរទេស និងជារដ្ឋមន្ត្រីកិច្ចការនារីអូស្ត្រាលី។

រដ្ឋមន្ត្រីការបរទេសទាំងពីរបានពិភាក្សាគ្នាលើបញ្ហាសំខាន់បន្ទាន់ដូចជា កិច្ចសហប្រតិបត្តិការក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់ នៃជំងឺរាតត្បាតកូវីដ-១៩ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធានាបាននូវការស្តារសេដ្ឋកិច្ចឡើងវិញឆាប់រហ័ស រួមទាំងបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនដែលជាចំណាប់អារម្មណ៍ និងការបារម្ភរួមគ្នា រួមទាំងការវិវត្តនៅក្នុងប្រទេសមីយ៉ាន់ម៉ាផងដែរ។

លោកស្រី ម៉ារីស ផេន បានរំលឹកឡើងវិញអំពីការប្តេជ្ញាចិត្តរបស់អូស្ត្រាលី ដើម្បីពង្រឹងកិច្ចសហការជាមួយប្រទេសកម្ពុជា និងបណ្តារដ្ឋជាសមាជិកអាស៊ាន នៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ ។

ដោយគូសបញ្ជាក់អំពីបំណងប្រាថ្នាដ៏មុតមាំរបស់អូស្ត្រាលីក្នុងការពង្រឹងភាពជាដៃគូ អាស៊ាន-អូស្ត្រាលី លោកជំទាវបានអះអាងជាថ្មី នូវការបន្តគាំទ្រដល់មជ្ឈភាពអាស៊ាននៅក្នុងនិម្មាបនកម្មតំបន់ដែលកំពុងតែវិវត្ត និងសមាហរណកម្មតំបន់។

លោកស្រី បានទន្ទឹងរង់ចាំកិច្ចប្រជុំកំពូលអាស៊ាន-អូ ស្ត្រាលី ប្រចាំឆ្នាំជាលើកដំបូងនៅខែតុលា ឆ្នាំ២០២១ ហើយនិងបានបញ្ជាក់ពីការគាំទ្រយ៉ាងពេញលេញសម្រាប់ការរៀបចំដោយជោគជ័យរបស់កម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២ ។

ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានថ្លែងអំណរគុណចំពោះប្រទេសអូស្ត្រាលីដែលបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា តាមរយៈវេទិកាទ្វេភាគី តំបន់ និងអនុតំបន់។

លោក ក៏បានកោតសរសើរប្រទេសអូស្ត្រាលីដែលបានគាំទ្រទាន់ពេលវេលាដល់ប្រទេសកម្ពុជា និងអាស៊ាន ក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាតកូវីដ-១៩ ។

លោក បានគូសបញ្ជាក់ថា ការកើនឡើងការចូលរួមប្រកបដោយអត្ថន័យរបស់ប្រទេសអូស្ត្រាលីជាមួយអាស៊ាន នឹងរួមចំណែកបន្ថែមទៀត យ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ច សមាហរណកម្មតំបន់ និងការបង្រួមគម្លាតអភិវឌ្ឍន៍នៅក្នុងតំបន់។

លោក ក៏បានរំលឹកជាថ្មីនូវការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការធានាឱ្យសម្រេចបាននូវសមិទ្ធផលប្រសើរក្នុងអំឡុងពេលកម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២ ជាមួយអាស៊ានទាំងមូលដែលជាគ្រួសារដ៏រឹងមាំ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការដោះស្រាយការប្រឈមនានា ដើម្បីសន្តិភាព ស្ថិរភាព មជ្ឈភាពអាស៊ាន និងការកសាងសហគមន៍។

លោក ក៏បានចែករំលែកអាទិភាពមួយចំនួនសម្រាប់ឆ្នាំក្រោយដែលកម្ពុជាធ្វើជាប្រធានអាស៊ាន រួមមានការខិតខំប្រឹងប្រែង ដើម្បីទទួលបានវឌ្ឍនភាពបន្ថែមទៀតនៅក្នុងការអនុវត្តគំនិតផ្តួចផ្តើមស្តារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ាន និងសមាហរណកម្មតំបន់ដែលស្របជាមួយចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ ខណៈពេលធ្វើការលើចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ លើកកម្ពស់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រី និងយុវជន នៅក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ និងដំណើរការកសាងសហគមន៍ ការពង្រឹងការរួមចំណែកដល់ការថែរក្សាសន្តិភាពរបស់អាស៊ាន។

ចំពោះបញ្ហាប្រទេសមីយ៉ាន់ម៉ា លោក ឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់អំពីការត្រៀមខ្លួនរបស់ប្រទេសកម្ពុជាក្នុងការធ្វើការជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន និងដៃគូអាស៊ានដទៃទៀត ដើម្បីគាំទ្រដល់ការវិលត្រឡប់ទៅរកមាគ៌ានៃប្រក្រតីភាព និងការផ្លាស់ប្តូរតាមរយៈប្រជាធិបតេយ្យរបស់ប្រទេសមីយ៉ាន់ម៉ា។

លោក ក៏បានបញ្ជាក់អំពីការកោតសរសើររបស់កម្ពុជា ចំពោះជំហាននានាដែលប្រ ទេសព្រុយណេ ក្នុងនាមប្រធានអាស៊ាននាពេលបច្ចុប្បន្ន កំពុងអនុវត្តតាមការឯកភាពគ្នាជាឯកចន្ទប្រាំចំណុចរបស់ថ្នាក់ដឹកនាំអាស៊ាន។

លោក ក៏បានបង្ហាញនូវទំនុកចិត្ត លើកម្លាំងនៃភាពចម្រុះរបស់អាស៊ាន ដើម្បីសម្រេចឱ្យបាននូវដំណោះស្រាយប្រកបដោយសន្តិវិធី តាមរយៈមាគ៌ាអាស៊ាន ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនមីយ៉ាន់ម៉ា និងការកសាងសហគមន៍អាស៊ាន។ រដ្ឋមន្ត្រីការបរទេសទាំងពីរ ក៏បានពិភាក្សាស៊ីជម្រៅពីការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីផងដែរ៕

# សត្វកែះ ជាប្រភេទសត្វមានដោយកម្រ ត្រូវថានចុះក្នុងបញ្ជីក្រហម IUCN





*អត្ថបទ៖ ផល សុផានិត*

ថ្មីៗនេះ ក្រុមអ្នកស្រាវជ្រាវរបស់ក្រសួងបរិស្ថាន បានរកឃើញវត្តមានសត្វកែះនៅក្នុងតំបន់ការពារធម្មជាតិនិងកម្ពុជាតាមរយៈការដាក់ម៉ាស៊ីនថតស្វ័យប្រវត្តិស្ថិតក្នុងក្របខណ្ឌនៃការសិក្សាចងក្រងទិន្នន័យប្រភេទសត្វកម្រៗនៅកម្ពុជា។ ប្រភេទសត្វកម្រនៅលើពិភពលោកនេះត្រូវបានកត់សម្គាល់ថាមានវត្តមាននៅក្នុងតំបន់ ការពារធម្មជាតិនៅកម្ពុជា ដែលនេះគឺជាការផ្តល់នូវទិន្នន័យមួយយ៉ាងសំខាន់សម្រាប់ការអភិរក្សជីវៈចម្រុះនៅកម្ពុជា ក៏ដូចជាសម្រាប់ពិភពលោកទាំងមូល។

យោងតាមក្រសួងបរិស្ថាន បានឱ្យដឹងថា មិនទាន់មានទិន្នន័យពិតប្រាកដថាមានសត្វកែះប៉ុន្មានក្បាលរស់នៅ ក្នុងប្រទេសកម្ពុជាទេ តែប្រភេទសត្វនេះមានដង់ស៊ីតេរស់នៅកម្រិតទាបបំផុតដោយសារតែជាសត្វកម្រ។ បច្ចុប្បន្ននេះ សត្វកែះកំពុងប្រឈមមុខនឹងការបាត់បង់ពូជដោយសារការបរបាញ់ ការដាក់អន្ទាក់និងការបាត់បង់ជីជម្រក។ អ្វីដែលធ្វើឱ្យសត្វកែះរងគ្រោះខ្លាំងដោយសារតែការប្រមាញ់ដើម្បីយកសាច់ ស្នែង ឆ្អឹងក្នុងការជួញដូរដោយសារតែជំនឿ។

ផ្នែកការសិក្សា កែះមានសម្បុរខ្មៅប្រផេះ និងរោមវែងស្តើង វាមានដងខ្លួនខ្លី ហើយជើងទាំង៤របស់វាវែង។ ផ្នែកខាងលើដងខ្លួនសម្បុរខ្មៅ និងផ្នែកក្រោមនៃជើងចាប់ពីក្បាលជង្គង់ចុះមានពណ៌ចម្រុះខ្មៅ ប្រផេះ លឿង។ នៅលើពំនូលក្បាលរហូតដល់ស្មារបស់វាមានរោមរឹងវែងៗសណ្ឋានដូចជាប្រែង។ វាមានស្នែងដូចសត្វពពែ ដុះកោងទៅក្រោយបន្តិច ប្រវែងប្រហែល ២៨០មម ពណ៌ខ្មៅ និងមានគន្លាក់ៗជារង្វង់នៅផ្នែកគល់។ កន្ទុយខ្លី ហើយមានរោមសំពោងពណ៌ខ្មៅប្រផេះ។

ការសិក្សា ចំពោះជីវសាស្ត្រវិញ សត្វកែះចូលចិត្តរស់នៅតំបន់ព្រៃភ្នំ ជ្រលង ផ្ទាំងថ្មខ្ពស់ៗដែលមានគម្របព្រៃ និងមានស្រទាប់រុក្ខជាតិថ្នាក់ក្រោមច្រើន។ កែះមានជើងយ៉ាងចំណាប់ក្នុងការដើរឡើងតាមផ្ទាំងថ្មចោត។ នៅពេលថ្ងៃវាចូលចិត្តសម្រាកតាមគម្លោតព្រៃក្រាស់ ហើយចេញរកស៊ីនៅពេលព្រលឹម ឬក្បាលព្រលប់។ វាចូលចិត្តស៊ីស្លឹករុក្ខជាតិ និងល្បះគ្រប់ប្រភេទ។ សត្វកែះចូលចិត្តយករូងភ្នំរាក់ៗធ្វើជាទីជម្រករបស់វា ហើយគេអាចសម្គាល់វត្តមានវាដោយសារគំនរលាមក។

ដោយសារតែកែះជាសត្វមានភាពរហ័សរហួន និងពូកែស្រង់ក្លិន ភ្នែកពូកែ និងរស់នៅតាមទីជម្រកស្ងាត់ដូច្នេះគេកម្រនឹងជួបប្រទះវាណាស់។ រដូវបន្តពូជសត្វកែះមាននៅខែតុលា និងខែធ្នូ ហើយកើតបានកូន ១ ជួនកាលភ្លោះមានដោយកម្របន្ទាប់ពីពពោះ៧ខែ។ កូនរស់នៅជាមួយមេវាស្ទើរពេញមួយឆ្នាំ ទើបចាកចេញ៕

# អ្វីដែលអ្នកមិនទាន់ដឹងអំពី មេរោគកូវីដបំលែងខ្លួនថ្មី ដែលតា (Delta)

Delta Variant ជាពពួកកូវីដ១៩ បំលែងខ្លួនថ្មី B.1.617.2 ដែលបានវាយលុកប្រទេសឥណ្ឌាក្នុងខែមេសា ឆ្នាំ២០២១។ វាមានអត្រាឆ្លងខ្ពស់ គឺ១០០០ដង បើប្រៀបធៀបនឹងកូវីដ១៩ធម្មតា ដែលពេលនេះ អង្គការសុខភាពពិភពលោកបានឲ្យដឹងថា វាបានបន្តចូលក្នុង៩៦ប្រទេសក្នុងពិភពលោក ហើយបានចូលមកដល់ប្រទេសកម្ពុជា តែមិនទាន់ចូលក្នុងសហគមន៍នៅឡើយទេ។

ក្នុងពេលថ្មីៗ ក្រសួងសុខាភិបាលប្រទេសកម្ពុជា បានអំពាវនាវ ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការរីកសាយភាយនៃមេរោគប្រភេទថ្មីនេះ។

តាមការស្រាវជ្រាវរបស់គ្រូពេទ្យនៅឥណ្ឌាដែលបានចុះផ្សាយដោយBBCបានឲ្យដឹងថា មេរោគបំលែងខ្លួនថ្មីនេះ បានជ្រៀតចូលទៅក្នុងកោសិការបស់សួត។ ក្រសួងសុខាភិបាលឥណ្ឌាបានឲ្យដឹងថាប្រភេទមេរោគបំលែងខ្លួនថ្មីនេះ រកឃើញដំបូងនៅក្នុងខែមេសា ដែលត្រូវបានយកចេញពីគំរូ៤០ក្នុងស្រុក៦នៃរដ្ឋចំនួន៣ក្នុងប្រទេស។

ក្នុងប្រទេសកម្ពុជាក្រសួងសុខាភិបាលបានចេញសេចក្ដីជូនដំណឹងអំពីការរកឃើញអ្នកឆ្លងមេរោគប្រភេទថ្មីនេះ ចំនួន៧៥ករណី ដែលជាករណីនាំចូល គឺចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១។

ចំណុចសំខាន់ៗដែលអ្នកគួរដឹង និងបង្ការខ្លួន

តាមការស្រាវជ្រាវរបស់អ្នកវេជ្ជសាស្ត្រនៃប្រទេសស្កុតឡេន បានឲ្យដឹងថា អ្នកដែលមិនទទួលបានវ៉ាក់សាំងបង្ការកូវីដ១៩ ងាយនឹងប្រឈមនឹងការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ២ដង បើធៀបនឹងអ្នកដែលបានទទួលវ៉ាក់សាំងរួចហើយ។ វាបង្កឲ្យមានជំងឺផ្សេងៗកើតមានឡើងច្រើនជាងមេរោគប្រភេទចាស់។




ចំពោះវ៉ាក់សាំងដែលអាចប្រឆាំងនឹងជំងឺប្រភេទថ្មីនេះ អ្នកស្រាវជ្រាវស្កុតឡេន បានឲ្យដឹងថា វ៉ាក់សាំងរបស់អាមេរិកអាចទប់ទល់នឹងវាបាន លើការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការស្លាប់។ ប៉ុន្តែមិនមានន័យថា ពួកគេមិនឆ្លងជំងឺនេះទៀតទេ។ បើក្រឡេកទៅមើលតួលេខរបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (CDC)របស់សហរដ្ឋអាមេរិកបានឲ្យដឹងថា ក៏មានអ្នកឆ្លង២០% នៃអ្នកឆ្លងសរុបក្នុងសហរដ្ឋអាមេរិក ដែលត្រូវបានរាយការណ៍កាលពីខែមិថុនា ឆ្នាំ២០២១នេះ។

CDC បានឲ្យដឹងទៀតថា ក្នុងចំណោមមនុស្ស១៦០លាននាក់ដែលទទួលវ៉ាក់សាំងគ្រប់ចំនួនដូសហើយ ក៏មាន៥.៤៩២ ករណីកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬបានស្លាប់ដោយសារកូវីដ១៩ ហើយអ្នកជំនាញមួយចំនួនបានផ្ដល់យោបល់ដល់ប្រជាជន ត្រូវពាក់ម៉ាស់គ្រប់ពេលដែលគេចេញទៅខាងក្រៅ ឬមានទំនាក់ទំនងជាមួយមនុស្សដែលមិនបានចាក់វ៉ាក់សាំង។

ម្យ៉ាងទៀតសហរដ្ឋអាមេរិកបានប្រកាសនឹងផ្ដល់វ៉ាក់សាំងដូសលើកទី៣ដល់ប្រជាជនរបស់ខ្លួន ដើម្បីបង្ការកូវីដ១៩បំលែងខ្លួនថ្មីផងដែរ។

ចំពោះវ៉ាក់សាំងទាំងពីរប្រភេទនេះអង្គការសុខភាពពិភពលោក បានឲ្យដឹងថា តាមការស្រាវជ្រាវរបស់ប្រទេសប្រេស៊ីលលើក្រុមមនុស្ស៧៥%ដែលបានទទួលវ៉ាក់សាំងស៊ីណូវ៉ាក់ គឺ មាន៤៩,៦% អាចទប់ទល់នឹងការឆ្លង។ ប្រសិទ្ធភាពក៏ត្រូវបានបង្ហាញនៅក្នុងការសិក្សា មួយនៅក្នុងទីក្រុងសៅប៉ូឡូដោយមានគំរូ៨៣%។

អង្គការសុខភាពពិភពលោកបានឲ្យដឹងទៀតថា ការប៉ាន់ស្មានប្រសិទ្ធភាពវ៉ាក់សាំងគឺ ៤៩,៦% បន្ទាប់ពីការចាក់យ៉ាងហោចណាស់មួយដូស ហើយបង្ហាញទៀតថា បន្ទាប់ពីការចាក់លើកទី ២ បាន២សប្ដាហ៍ គឺមានប្រសិទ្ធិភាព ៥០,៧%។ អង្គការនេះ បានឲ្យដឹងទៀតថា នៅពេលមានទិន្នន័យថ្មី WHO នឹងធ្វើបច្ចុប្បន្នភាពអនុសាសន៍នានាបន្ថែម។

តើមានអាការៈអ្វីខ្លះដែលបញ្ជាក់ថា មានជំងឺកូវីដ១៩ បំលែងខ្លួនថ្មី ប្រភេទដែលតា?

គ្រូពេទ្យនៅប្រទេសឥណ្ឌាបានស្រង់នូវអាការៈរបស់អ្នកជំងឺឆ្លងមេរោគដែលតានេះ ដែលមានជាទូទៅដូចជា៖ ឈឺពោះ ចង្អោរ ក្អួត បាត់បង់ចំណង់អាហារ បាត់បង់ការស្ដាប់ និងឈឺសន្លាក់។

តើមានវិធីអាចការពារជំងឺប្រភេទបំលែងខ្លួនថ្មីដែលតានេះបានទេ?

កត្តាមួយចំនួនដែលអាចចៀសពីជំងឺនេះបានរួមមាន៖ ការថែរក្សាខ្លួន ពីជំងឺប្រភេទបំលែងខ្លួនថ្មីនេះ គឺមិនខុសពីមេរោគកូវីដ១៩ចាស់នោះទេ។ ៣កុំ និង៣ការពាររបស់រដ្ឋាភិបាល និងវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាលត្រូវអនុវត្តឲ្យបានហ្មត់ចត់ជានិច្ច។

៣ការពារ៖ ពាក់ម៉ាស់ឲ្យជិតចម្រុះនិងមាត់ ជាពិសេសនៅកន្លែងដែលមានមនុស្សច្រើន និងកន្លែងបិទជិត, រក្សាគម្លាត ២ម៉ែត្រឡើងទៅក្នុងការទំនាក់ទំនង និងលាងដៃនិងសាប៊ូ ដែល ឬអាល់កុលឲ្យបានញឹកញាប់

៣កុំ៖ កុំទៅកន្លែងដែលមានមនុស្សប្រមូលផ្ដុំច្រើន, កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល និងកុំចាប់ដៃគ្នា កុំកៀកស្មាគ្នា។

វិធានសុខាភិបាល៖

សំអាតបរិវេណដែលមានមនុស្សចេញចូលឲ្យបានស្អាត តាមដានពត៌មានអំពីកូវីដ១៩ ហើយបើមិនចាំបាច់កុំចេញទៅខាងក្រៅ រស់នៅស្អាតជានិច្ច៕

# រដ្ឋាភិបាលជប៉ុនផ្ដល់រថយន្តគិលានសង្គ្រោះ ៣០គ្រឿងដល់កម្ពុជា



អត្ថបទ៖ អមរិន្ទ ដានុត

ជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងនឹងការឆ្លងវីរុសក្លូណាប្រភេទថ្មី នៅលើសាកលលោក រដ្ឋាភិបាលជប៉ុនបានសម្រេចផ្ដល់រថយន្តគិលានសង្គ្រោះចំនួន៣០គ្រឿងបន្ថែមទៀតជូនដល់ព្រះរាជាណាចក្រកម្ពុជា។

នេះគឺជាការប្រគល់បន្ថែមលើរថយន្តគិលានសង្គ្រោះចំនួន៧០គ្រឿងដែលបានផ្ដល់ជូនកន្លងរួចមកហើយ។រថយន្តគិលានសង្គ្រោះទាំង៣០គ្រឿងនេះ បានបញ្ជូនទៅកាន់មូលដ្ឋានសុខាភិបាលជាច្រើនក្នុងសប្ដាហ៍នេះ។ នេះបើយោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ស្ថានទូតជប៉ុនប្រចាំកម្ពុជានៅថ្ងៃទី១៦ ខែកក្កដា នេះ។

ជំនួយនេះ គឺផ្អែកលើវិធានការណ៍កិច្ចសហប្រតិបត្តិការ ដែលបានដាក់ចេញជាមួយបណ្ដាប្រទេស អាស៊ានដែលត្រូវបានប្រកាសដោយលោកអតីតនាយករដ្ឋមន្ត្រីស៊ីនហ្សូ អាបិនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេសកាលពីខែមេសាឆ្នាំមុន។ គំនិតផ្ដួចផ្ដើមនេះគឺជាផ្នែកមួយនៃការងារជាច្រើនរបស់រដ្ឋាភិបាលជប៉ុនក្នុងការប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ១៩ លើកម្រិតសាកល។

សេចក្ដីប្រកាសដដែលបានឱ្យដឹងថា រហូតមកដល់ពេលនេះ ឆ្លើយតបនឹងការស្នើរសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ជប៉ុនបានផ្គត់ផ្គង់គ្រឿងបរិក្ខារវេជ្ជសាស្ត្រដូចជារថយន្តគិលានសង្គ្រោះចំនួន១០០គ្រឿង ឧបករណ៍ត្រួតពិនិត្យកាំរស្មីអ៊ិចចំនួន១០ ឧបករណ៍ធ្វើរោគវិនិច្ឆ័យអ៊ុលត្រាសោនចំនួន២៦ ឧបករណ៍ផលិតអុកស៊ីសែនចំនួន៦៣ និងគ្រែសង្គ្រោះបន្ទាន់ចំនួន១០០គ្រែ និងគ្រឿងបរិក្ខារវេជ្ជសាស្ត្រ ជាច្រើនផ្សេងទៀតជូនដល់កម្ពុជា។

លើសពីនេះទៀត នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ឯកឧត្តមម៉ូតេហ្គិ តូស៊ីមីត្សឹ រដ្ឋមន្ត្រីការបរទេសជប៉ុនបានប្រកាសថាជប៉ុននឹងផ្ដល់វ៉ាក់សាំង AstraZeneca ដែលផលិតនៅប្រទេសជប៉ុន ប្រមាណ ១,០០០,០០០ ដូសជូនដល់កម្ពុជាតាមរយៈCOVAX Facility។ វ៉ាក់សាំងទាំងនេះនឹងត្រូវបានដឹកជញ្ជូនមកដល់រាជធានីភ្នំពេញក្នុងពេលដ៏ឆាប់ខាងមុខនេះ នៅពេលដែលការរៀបចំភស្តុភារដោយ COVAX Facility ត្រូវបានបញ្ចប់។

ប្រទេសជប៉ុននឹងបន្តកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្ដល់នូវឧបករណ៍ចាំបាច់ ហើយជប៉ុនសង្ឃឹមថាការផ្គត់ផ្គង់ទាំងនេះនឹងអាចជួយដល់ភាគីពាក់ព័ន្ធផ្នែកសុខាភិបាលនៅកម្ពុជាដែលកំពុងប្រយុទ្ធប្រឆាំងជាមួយនឹងជម្ងឺកូវីដ១៩៕

# កុមារនិងយុវវ័យក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ទាននឹងកំពុងទទួលការចាក់វ៉ាក់សាំងជំងឺកូវីដ១៩

*អត្ថបទ៖ ផល សុផានិត*

កុមារ និងយុវវ័យចាប់ពីអាយុ ១២ឆ្នាំ ដល់ ១៧ឆ្នាំ បាននឹងកំពុងទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ក្នុងពេលដ៏ឆាប់ខាងមុខនេះ ដើម្បីបង្កើតភាពស៊ាំក្នុងសង្គម និងឈានទៅដល់ការបើកសកម្មភាពសង្គមឱ្យកាន់តែទូលាយ ជាពិសេសការបើកសាលារៀនឡើងវិញ។

នេះបើតាម សារសម្លេងពិសេសរបស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ប្រកាសដាក់ចេញផែនការចាក់វ៉ាក់សាំងជំងឺកូវីដ១៩ នៅព្រឹកថ្ងៃទី ១៦ ខែកក្កដា កន្លងមកនេះ។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ៖«ដោយមានការគិតគូរយ៉ាងម៉ត់ចត់ទៅលើបរិយាកាសភាពស៊ាំក្នុងសង្គម និងគិតគូរទៅដល់អនាគតរបស់កុមារ និងយុវវ័យ។ ជាពិសេសផ្ដោតការយកចិត្តទុកដាក់ទៅលើសុខុមាលភាពពាក់ព័ន្ធការបើកឡើងវិញនូវសាលារៀន ដែលជាការបាត់បង់ដ៏ធំធេងរបស់ពិភពលោក ក៏ដូចជាកម្ពុជាក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស ដែលសាលាត្រូវបានបិទក្នុងរយៈពេលយូរ ដូច្នេះពិតប្រាកដណាស់ យើងមានតម្រូវការចាក់វ៉ាក់សាំងសម្រាប់កុមារ និងយុវវ័យចាប់ពីអាយុ ១២ឆ្នាំ ដល់ ១៧ឆ្នាំ»។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ដែរថា ក្មេងអាយុពី ១២ឆ្នាំ ដល់ ១៧ឆ្នាំ មានចំនួនប្រមាណ ១លាន ៩សែន ឬនិយាយជាលេខមូលស្មើនឹង ២លាននាក់។ តាមរយៈចំនួននេះ កម្ពុជាត្រូវការវ៉ាក់សាំងប្រមាណ ៤លានដូសបន្ថែមទៀត។

សម្ដេចតេជោ បានអំពាវនាវថា ៖«ខ្ញុំសូមឱកាសនេះអំពាវនាវដល់មាតាបិតា អាណាព្យាបាលកុមារត្រៀមខ្លួន ដើម្បីនាំកូននាំចៅទៅចាក់វ៉ាក់សាំងនៅពេលវេលាដែលបានមកដល់។ យើងចង់ឱ្យមានភាពស៊ាំនៅក្នុងសង្គម ដើម្បីឈានទៅដល់ការបើកវិញនូវសង្គមសេដ្ឋកិច្ច ពិសេសគឺសាលារៀនដែលយើងបានបិទសាលា ហើយឱ្យរៀនពីចម្ងាយតាមរយៈប្រព័ន្ធអនឡាញ។ រឿងនេះជាការខាតបង់មួយសម្រាប់យើង។ បើសិនយើងបានចាក់វ៉ាក់សាំងឱ្យកុមារ និងយុវជន យ៉ាងហោចណាស់យើងអាចបើកសាលាចាប់ពីអនុវិទ្យាល័យឡើងទៅ»។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ការចាក់វ៉ាក់សាំងនេះ នៅតែឈរលើគោលការណ៍ស្ម័គ្រចិត្ត។ តែសម្ដេចសង្ឃឹមថា តាមការយល់ដឹង និងស្មារតីចូលរួមរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ គឺមាតាបិតា និងអាណាព្យាបាលនឹងនាំកូនៗទៅទទួលវ៉ាក់សាំង៕

# សាសនទូត PIME ដំបូង មកកម្ពុជាទទួលមរណភាព

«អ្នកដែលបានជួបលោកពុក បានភ្លក់និងស្គាល់រសជាតិនៃស្ថានបរមសុខ។ នេះជាអ្វីដែលព្រះជាម្ចាស់សង្ឃឹមយើងម្នាក់ៗ ហើយតាមគំរូលោកពុកនាំឲ្យយើងយល់ថា យើងត្រូវច្បាស់លាស់នៅក្នុងគោលដៅនេះ»។ នេះសម្ដីរបស់លោកបូជាចារ្យឃុំាងលូកា ប្រធានក្រុមគ្រឹះស្ថានសម្ដេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME)នៅកម្ពុជា នៅក្នុងពិធីបុណ្យសពរបស់លោកបូជាចារ្យតូនី វីនដ្រាមីន កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ នៅព្រះវិហារសន្តយ៉ូសែប(ផ្សារតូច) នារាជធានីភ្នំពេញ។

ក្នុងធម្មទេសនា ក្នុងពិធីបុណ្យដែលមានអ្នកចូលរួមតិចតួចនៅក្នុងវិហារ ព្រោះតែការរាលដាលនៃជំងឺកូវីដ១៩ លោកបូជាចារ្យ ឃុំាងលូការ តាវ៉ូឡា មានប្រសាសន៍ទៀតថា លោកបូជាចារ្យតូនីមានទស្សនៈមួយយ៉ាងច្បាស់លាស់ ហើយគាត់តែងតែយល់និងផ្ទេរគំនិតមួយដល់យើងទាំងអស់គ្នាដែលបានជួបគាត់ «គឺសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ត្រូវតែជះឥទ្ធិពលដល់ជីវិតប្រចាំថ្ងៃរបស់បងប្អូនរបស់យើងម្នាក់ៗ»។

«នៅពេលនេះ យើងសូមថ្វាយវិញ្ញាណក្ខន្ធលោកពុកតូនីទៅក្នុងព្រះហស្ដរបស់ព្រះជាម្ចាស់។ សូមលោកឪពុកទទួលសេចក្ដីសុខសាន្តនៅស្ថានបរមសុខ ជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច» លោកបូជាចារ្យឃុំាងលូកាបន្ថែម។

ក្នុងកិច្ចការបម្រើព្រះជាម្ចាស់ចាប់តាំងពីតែងតាំងជាបូជាចារ្យ លោកបូជាចារ្យតូនី ខិតខំនិងយកចិត្តទុកដាក់ខ្ពស់ចំពោះការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូ ដោយបម្រើអ្នកតូចតាច ដោយបន្ទាបខ្លួន និងមានចិត្តសុភាពរាបសារ។ លោកបូជាចារ្យតូនី បានបម្រើនៅក្នុងព្រះសហគមន៍នៅប្រទេសបង់ក្លាដេស អស់រយៈពេល១៥ ឆ្នាំ ហើយបានបន្តដំណើរមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩០ ដោយបានជួយកសាង និងបង្កើតព្រះសហគមន៍មួយចំនួន ជួយគាំទ្រដល់កិច្ចការងារក្នុងសង្គម ជាពិសេសគឺឲ្យមនុស្សតូចតាចមានជីវិតរស់នៅសមរម្យ ក្រោយពេលប្រទេសកម្ពុជាបានរួចផុតពីសង្គ្រាមប្រល័យពូជសាសន៍ប៉ុលពត រហូតដល់ពេលបច្ចុប្បន្ន។

ក្នុងពេលនោះដែរ លោកអភិបាលអូលីវីយេ៉ ផ្មិតហស្លេរ ជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ថ្លែងអំណរគុណដល់លោកបូជាចារ្យតូនី និងនឹករលឹកអំពីក្រុមមនុស្សជាច្រើនដែលលោកបូជាចារ្យតូនីបានជួយគាំទ្រ តាមរយៈសកម្មភាពរបស់លោកក្នុងរយៈពេលជាង៣០ឆ្នាំមកនេះ។ ក្នុងនោះរួមមាន ក្រុមគ្រួសារសាសនទូទ PIME បុគ្គលិកនិងបងប្អូនដែលបានធ្វើការងារនិងទទួលផលពីអង្គការមនុស្សលោកថ្មី និងព្រះសហគមន៍ដែលលោកបានណែនាំ។

លោកអភិបាលបានឲ្យដឹងថា តាមរយៈកិច្ចការរបស់លោកបូជាចារ្យតូនី «ណែនាំឲ្យមនុស្សយ៉ាងច្រើន ជាពិសេសបងប្អូនរបស់យើងតូចតាច ដែលសង្គមពូកែភ្លេច រកឃើញសេចក្ដីសង្ឃឹមដ៏ពិតប្រាកដ»។




លោកអភិបាលអូលីវីយេ៉ មានប្រសាសន៍ទៀតថា លោកតូនីជាមនុស្សសាមញ្ញ ដាក់ខ្លួនជានិច្ចដើម្បីបម្រើបងប្អូនឯទៀតៗ។ យើងអធិដ្ឋានដើម្បីឲ្យគំរូនៃជីវិតរបស់លោកតូនី ណែនាំឲ្យយើងមានកំលាំងកាយកំលាំងចិត្ត ដើម្បីបន្តធ្វើដំណើរលើផែនដីនេះ ។ លោកអភិបាលបន្ថែមថា «ពិតមែនលោកតូនីបានធ្វើការងារអស្ចារ្យលើផែនដីនេះ ដោយពោរពេញដោយសេចក្ដីស្រឡាញ់ដ៏ធំធេង»។

បងស្រីប៉ាទីណា នៃក្រុមគ្រួសារបងស្រីមេត្តាករុណា (Missionary of Charity Sisters) បានធ្វើសក្ខីភាពអំពីលោកបូជាចារ្យតូនី យ៉ាងនេះថា លោកបូជាចារ្យតូនី ជាអ្នកមនុស្សមានជំនឿរឹងមាំ និងពិតជាសាសនទូតយ៉ាងពិតប្រាកដ ជាមនុស្សស្ដាប់បង្គាប់និងជឿទុកចិត្ត។ នៅគ្រាដំបូងនោះ អ្នកម្ដាយតេរេសាបានស្នើសុំលោកឲ្យមកបម្រើការងារនៅក្នុងប្រទេសកម្ពុជា គាត់ឆ្លើយមិនស្ទាក់ស្ទើរចំពោះបេសកកម្មនេះ គឺបានចូលរួមជាមួយយើងតាមព្រះបំណងរបស់ព្រះជាម្ចាស់ ទោះបីជាគាត់និងក្រុមបងស្រីមេត្តាករុណាមិនដឹងថា តើអនាគតទៅមុខនឹងយ៉ាងណានៅក្នុងប្រទេសកម្ពុជាក៏ដោយ។

«មានថ្ងៃមួយក្រោយអភិបូជា លោកពុកបានលេងជាមួយក្មេងៗក្នុងមណ្ឌលរបស់យើង។ មានក្មេង២នាក់ពិការភ្នែក លោកពុកបានជួយពួកគេឲ្យចូលរៀន ហើយពេលនេះ ពួកគេជាគ្រូបង្រៀន និងមានគ្រួសារអស់ហើយ» បងស្រីបញ្ជាក់។

បងស្រីប៉ាទីណាបន្ថែមថា លោកឪពុកតែងតែទៅជួបនិងថ្វាយអភិបូជាជាភាសាអង់គ្លេសនៅក្នុងពន្ធនាគារជាមួយក្រុមបងប្រុសមេត្តាករុណាផងដែរ។

លោកបូជាចារ្យ តូនី វីនដ្រាមីន ជាបូជាចារ្យនៃគ្រឹះស្ថានសម្ដេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME)។ លោកប្រសូតនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៤២ នៅបាដូវ៉ា ប្រទេសអ៊ីតាលី។ លោកទទួលអគ្គសញ្ញា តែងតាំងជាបូជាចារ្យ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៦៩។ លោកទៅបម្រើកិច្ចការជាសាសនទូត នៅប្រទេសបង់ក្លាដែសអស់រយៈពេល ១៥ ឆ្នាំ ពីឆ្នាំ១៩៧៥ - ១៩៩០។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩០ លោកឪពុក តូនីបានមកដល់ ប្រទេសកម្ពុជាដើម្បីរួមដំណើរជាមួយ បងស្រីមេត្តាករុណា នៃអ្នកម្ដាយ តេរេសា នៅគុលគូថា តាមការអញ្ជើញរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃរដ្ឋកម្ពុជា។ លោកឪពុកជាសាសនទូត PIME ដំបូងគេដែលបានមកដល់ប្រទេសកម្ពុជា។

លោកបានជួយពង្រឹងគុណភាពអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញទី២។ លោកធ្វើកិច្ចការអភិវឌ្ឍសហគមន៍ ផ្នែកសុខភាព បម្រើជនមានពិការភាព ជួយផ្ដល់ឱកាសឲ្យកុមារ និងយុជនមានការអប់រំសិក្សាខ្ពង់ខ្ពស់ ផ្លាស់ប្ដូរជីវិតរស់នៅរបស់ពួកគេឲ្យប្រសើរឡើង។ ដើម្បីសម្រេចគោលដៅខាងលើនេះបាន លោកឪពុកតូនី បានបង្កើតអង្គការ ក្រៅរដ្ឋាភិបាលមួយ ឈ្មោះថា «មនុស្សលោកថ្មី » នៅក្នុងឆ្នាំ១៩៩៣។ អង្គការនេះជាឧបករណ៍មួយ បង្ហាញពីវត្តមានរបស់ព្រះជាម្ចាស់ នៅកណ្ដាលចំណោមប្រជាជន។ លោកទៅសួរសុខទុក្ខជនជាប់ឃុំ និងលើកទឹកចិត្តដល់អ្នកជាប់ឃុំជាជនបរទេស។

លោកបង្រៀនវិទ្យាផ្សេងៗក្នុងព្រះសហគមន៍ និងដល់និស្សិតទេវិទ្យាល័យ។ លោកបម្រើតាមព្រះវិហារ នានានៅពោធិចិនតុង និង អំពៅព្រៃ ជាដើម។

លោកជាសមាជិក សកម្ម នៃគណៈកម្មការអន្តរភូមិភាគ ក្នុងកិច្ចការបកប្រែ សៀវភៅក្បួនពិធីបុណ្យ អភិបូជាថ្មី ដែលយើងកំពុងប្រើប្រាស់សព្វថ្ងៃ។ មានកិច្ចការជាច្រើនទៀតដែលយើងមិនអាចរៀបរាប់អស់។

នៅរាត្រីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ព្រះជាម្ចាស់បានត្រាស់ហៅលោកទៅឯព្រះអង្គវិញ ក្នុងជន្មាយុ ៧៩ឆ្នាំ៕



# ប្រវត្តិសង្ខេប លោកឪពុក
# តូនី វីនដ្រាមីន

លោកឪពុក តូនី វីនដ្រាមីន ជាបូជាចារ្យ នៃគ្រឹះស្ថានសម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME)។ លោកប្រសូតនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៤២ នៅបាដូវ៉ េប្រទេសអ៊ីតាលី។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៦៩ ។

លោកទៅបម្រើកិច្ចការជាសាសនទូត នៅប្រទេសបង់ក្លាដែសអស់រយៈពេល ១៥ ឆ្នាំ ពីឆ្នាំ១៩៧៥ - ឆ្នាំ១៩៩០ ។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩០ លោកឪពុក តូនីបានមកដល់ ប្រទេសកម្ពុជា ដើម្បីរួមដំណើរជាមួយ បងស្រីមេត្តាករុណា នៃអ្នកម្តាយ តេរេសា នៅគុលគូថា តាមការអញ្ជើញរបស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃរដ្ឋកម្ពុជា។

លោកឪពុកជាសាសនទូត PIME ដំបូងគេដែលបានមកដល់ប្រទេសកម្ពុជា។ គ្រានោះគ្មានព្រះវិហារទេ លោកថ្វាយអភិបូជា រួមជាមួយបងស្រីនៅក្នុងផ្ទះ។ ក្រោយមកប្រទេសកម្ពុជាមានសេរីភាពខាងជំនឿឡើងវិញ។ លោកបានរួមដំណើរជាមួយបូជាចារ្យសាសនទូតផ្សេងទៀត និងគ្រីស្តបរិស័ទ កសាងព្រះសហគមន៍កម្ពុជាឡើងវិញ។

ក្នុងរយៈពេលជាង៣០ឆ្នាំនៅក្នុងប្រទេសកម្ពុជា លោកឪពុក តូនីបានខិតខំអស់ពីកម្លាំងកាយចិត្ត ផ្តល់សក្ខីភាពអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគ្រីស្តចំពោះមនុស្សទាំងអស់។ លោកមានជំនឿយ៉ាងរឹងមាំលើព្រះជាម្ចាស់។ លោកបម្រើដោយចិត្តសុភាពរាបសា និងយកចិត្តទុកដាក់ខ្ពស់។ លោកបានជួយពង្រឹងគុណភាពអប់រំ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញទី២។

លោកធ្វើកិច្ចការអភិវឌ្ឍសហគមន៍ ផ្នែកសុខភាព បម្រើជនមានពិការភាព ជួយផ្តល់ឱកាសឲ្យកុមារ និងយុជនមានការអប់រំសិក្សាខ្ពង់ខ្ពស់ ផ្លាស់ប្តូរជីវិតរស់នៅរបស់ពួកគេឲ្យប្រសើរឡើង។ ដើម្បីសម្រេចគោលដៅខាងលើនេះបាន លោកឪពុកតូនី បានបង្កើតអង្គការ ក្រៅរដ្ឋាភិបាលមួយ ឈ្មោះថា «មនុស្សលោកថ្មី » នៅក្នុងឆ្នាំ១៩៩៣។

អង្គការនេះជាឧបករណ៍មួយ បង្ហាញពីវត្តមានរបស់ព្រះជាម្ចាស់នៅកណ្តាលចំណោមប្រជាជន។ លោកទៅសួរសុខទុក្ខជនជាប់ឃុំ និងលើកទឹកចិត្តដល់អ្នកជាប់ឃុំជាជនបរទេស។ លោកបង្រៀនវិទ្យាផ្សេងៗក្នុងព្រះសហគមន៍ និងដល់និស្សិតទេវិទ្យាល័យ។ លោកបម្រើតាមព្រះវិហារ នានានៅពោធិចិនតុង និង អំពៅព្រៃ ជាដើម។ លោកជាសមាជិក សកម្ម នៃគណៈកម្មការអន្តរភូមិភាគ ក្នុងកិច្ចការបកប្រែសៀវភៅក្បួនពិធីបុណ្យ អភិបូជាថ្មី ដែលយើងកំពុងប្រើប្រាស់សព្វថ្ងៃ។ មានកិច្ចការជាច្រើនទៀតដែលយើងមិនអាចរៀបរាប់អស់។

សូមអរគុណលោកឪពុក តូនី វីនដ្រាមីន ដែលបានថ្វាយជីវិតទាំងក្នុងព្រះហស្តរបស់ព្រះជាម្ចាស់សម្រាប់ បម្រើព្រះសហគមន៍កាតូលិកនៅកម្ពុជាភូមិភាគភ្នំពេញ និងប្រជាជនកម្ពុជាដោយចិត្តមេត្តាករុណា សន្តោសប្រោសប្រណី ស្លូតបូត បន្ទាបខ្លួន និងភក្តីភាពយ៉ាងពិតប្រាកដ ក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដោយឥតព្រំដែន រហូតដល់ថ្ងៃលោកឪពុកមានជំងឺធ្ងន់ ហើយព្រះជាម្ចាស់ត្រាស់ហៅលោក ត្រឡប់ទៅឯព្រះអង្គវិញ នៅរាត្រីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ក្នុងជន្មាយុ ៧៩ឆ្នាំ៕










# អភិបាលព្រះសហគមន៍ បញ្ញាវន្តកម្ពុជា និងគ្រីស្តបរិស័ទចងចាំ លោកឪពុកតូនី វិនត្រាមីន នៃក្រុមគ្រួសារ PIME

*អត្ថបទ៖ ដាលីស*

លោកបូជាចារ្យ តូនី វីនជ្រាមីន បានទទួលមរណភាព កាលពីយប់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ក្នុងជន្មាយុ ៨០ឆ្នាំ ដោយរោគាពាធ នៅមន្ទីរពេទ្យមួយក្នុងរាជធានីភ្នំពេញ។ ការបាត់បង់រូបលោកបានធ្វើឱ្យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ គ្រឹះស្ថានសម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME) នៅកម្ពុជា គ្រីស្តបរិស័ទកាតូលិក បញ្ញាវន្តកម្ពុជា មានសេចក្តីក្តុកក្តួល និងសោកស្តាយជាពន់ពេក។







លោកអភិបាល អូលីវីយេ៉ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បានលើកឡើងថា លោកឪពុកតូនី បានថ្វាយជីវិតទាំងស្រុង ដើម្បីបម្រើព្រះអម្ចាស់យេស៊ូគ្រីស្ត និងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ក្នុងមុខងារជាបូជាចារ្យសាសនទូត អស់រយៈពេល៥២ឆ្នាំ ក្នុងនោះនៅប្រទេសបង់ក្លាដែសពីឆ្នាំ១៩៧៥-១៩៩០ និងនៅប្រទេសកម្ពុជា ចាប់តាំងពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៩០ រហូតដល់ដង្ហើមចុងក្រោយរបស់លោកនាពេលនេះ។

លោកអភិបាលបានមានប្រសាសន៍ថា ៖ «យើងមានចិត្តដ៏ស្មោះស្ម័គ្រក្នុងការអធិដ្ឋានសម្រាប់ក្រុមគ្រួសាររបស់លោកឪពុក តូនី នៅប្រទេសអ៊ីតាលី និងជាពិសេសសម្រាប់អស់លោកបូជាចារ្យនៃគ្រឹះស្ថានសម្តេចប៉ាបសម្រាប់សាសនទូតក្រៅប្រទេស (PIME) ដែលជាបងប្អូនដ៏ជាទីស្រឡាញ់របស់លោកនៅក្នុងប្រទេសកម្ពុជា និងនៅជុំវិញពិភពលោក»។

ក្នុងប្រទេសកម្ពុជា លោកតូនី មានសកម្មភាពជាច្រើន ចូលរួមអភិវឌ្ឍន៍ប្រទេសនេះ ដូចជា ក្នុងវិស័យអប់រំសិក្សា ការអភិវឌ្ឍសហគមន៍ លើកកម្ពស់ជនមានពិការភាព ជួបប្រឹក្សាអ្នកជាប់ឃុំឃាំងក្នុងពន្ធនាគារ និងបម្រើព្រះសហគន៍ជាដើម។ យុវជនកម្ពុជាជាច្រើនបានប្តូរវាសនារបស់ខ្លួនតាមរយៈសកម្មភាពរបស់លោកតូនី។

បណ្ឌិត ប៉ាន់ វុត្ថា មន្ត្រីផ្នែកទស្សនវិជ្ជានៅរាជបណ្ឌិត្យសភា បានប្រាប់ឲ្យដឹងថា លោកបានស្គាល់លោកតូនី តាំងពីឆ្នាំ១៩៩៧មក ក្នុងពេលលោកជួយដល់មហាវិទ្យាល័យសង្គមសាស្ត្រ។ លោកថា លោកតូនី បានជួយឧបត្ថម្ភការបណ្តុះបណ្តាល និងជួយរកគ្រូពីក្រៅប្រទេសមកបណ្តុះបណ្តាលទាំងគ្រូ និងសិស្សនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។



លោកបណ្ឌិត ប៉ាន់ វុត្ថា បានបន្តថា ៖ «រយៈពេល ៥ឆ្នាំ ខ្ញុំបានទទួលការបណ្តុះបណ្តាលប្រមាណជា២០គ្រូ ក្នុងចំណោម៦០គ្រូ មកពីក្រៅប្រទេស ដែលលោកឪពុកតូនីបានរៀបចំនៅក្នុងវគ្គបណ្តុះបណ្តាលនោះ»។

លោកបណ្ឌិតបានបញ្ជាក់បន្ថែមថា លោកតូនីមានសន្តានចិត្តល្អមិនប្រកាន់សាសនា មិនប្រកាន់ជាតិសាសន៍ឡើយ។ វត្តមានរបស់គាត់នៅក្នុងប្រទេសកម្ពុជា ជាគំរូនៃសប្បុរសធម៌ និងបង្កើតកម្មវិធីអប់រំ ដោយមិនអូសទាញបង្ខំឱ្យចូលសាសនា ប៉ុន្តែជាការបណ្តុះបណ្តាលធនធានមនុស្សដើម្បីអភិវឌ្ឍកម្ពុជា។

លោកបានថ្លែងថា ៖ «ខ្ញុំពិតជាសោកស្តាយខ្លាំងណាស់ ដែលបាត់បង់ធនធានមនុស្ស និងជនគំរូមួយរូបនេះ។ ខ្ញុំសូមចូលរួមមរណៈទុក្ខដ៏ក្រៀមក្រំនេះ និងសូមបួងសួងសូមដួងវិញ្ញាណក្ខន្ធរបស់គាត់បានទៅកាន់ទីដ៏សមគួរ»។

ចំណែកលោកស្រី ឌុម សាខន ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកទស្សនវិជ្ជា ក៏បានរៀបរាប់ផងដែរថា លោកស្រីបានស្គាល់លោកតូនីតាំងពីឆ្នាំ២០០០មក។ អ្នកនៅខាងផ្នែក (តេប៉ាតម៉ង់)ទស្សនវិជ្ជាទាំងអស់មានការចងចាំជាច្រើនអំពីលោកឪពុកតូនីនេះ។

លោកស្រីបានប្រាប់ថា ៖ «សម្រាប់ខ្ញុំ ប្រសិនបើគ្មានលោកឪពុកតូនីទេ ខ្ញុំក៏មិនមានថ្ងៃនេះដែរ។ តាំងពីខ្ញុំស្គាល់គាត់មក ខ្ញុំឃើញគាត់ជាមនុស្សមានយុត្តិធម៌ មិនប្រកាន់ច្រើន ចេះដាក់ខ្លួន រួសរាយរាក់ទាក់ ជាអ្នកចង្អុលបង្ហាញនូវអ្វីដែលត្រឹមត្រូវ។ គាត់បានចែករំលែក

***អានបន្តទំព័រ-១៥...***

# អង្គការជេស្វីតសឺវីសដាំកូនឈើរំលឹកអ្នកបរិស្ថាន





*អត្ថបទ៖ CSC*

ថ្ងៃម្សិលមិញនេះអង្គការជេស្វីតសឺវីសកម្ពុជា(JSC) បានរៀបចំកម្មវិធីដាំកូនឈើ ក្នុងឱកាសបុណ្យ វុក្ខទិវា ជាតិ ៩ កក្កដា ២០២១ នៅក្នុងបរិវេណមជ្ឈមណ្ឌលបន្ទាយព្រាបថ្មី ស្ថិតនៅក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ។

លោកបូជាចារ្យ ឡាមុហ្គ ដែនីស កាព្រីអែល ឡង់ (កាប៊ី) ជាប្រធានអង្គការ JSC មានប្រសាសន៍ថា យើងដាំដើមឈើនៅថ្ងៃនេះដើម្បីរំឭកអំពីគុណតម្លៃនៃព្រៃឈើ និងបញ្ជាក់ថា យើងមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយនឹងធនធានធម្មជាតិ។

លោកមានប្រសាសន៍បន្ថែមទៀតថា យើងចងចាំផងដែរនូវមនុស្សដែលបានធ្វើការយ៉ាងសកម្មក្នុងការពារ និងថែរកសា ព្រៃឈើ ដោយតស៊ូប្រឆាំងជាមួយនឹងការកាប់បំផ្លាញ ព្រៃឈើ និងទង្វើខុសច្បាប់នានា។

លោកបន្ថែមថា ជាមួយគ្នានេះផងដែរយើងក៏រំឭកអំពីយុវជន និងអស់អ្នកដែលមានបេះដូងស្រឡាញ់ធនធានធម្មជាតិ។ សូមឲ្យ ឆន្ទៈ ដែលស្រឡាញ់នោះ ណែនាំឲ្យពួកគេ ចេះបញ្ចេញសកម្មភាពការពារ អ្នកក្រីក្រ និងបរិស្ថាន៕

# កញ្ញា ព្រំ សុខនា ៖ «ព្រះសហគមន៍បង្រៀនខ្ញុំឲ្យចេះស្រឡាញ់ និងចេះជួយអ្នកជិតខាង»



*អត្ថបទ៖ ឆាក លាំង*

កញ្ញា ព្រំ សុខនា វ័យ២៥ឆ្នាំ ជាកូនស្រីម្នាក់ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៩នាក់ ក្នុងគ្រួសារពុទ្ធបរិស័ទមួយ មានស្រុកកំណើតរស់នៅក្នុងស្រុកគីរីវង់ ខេត្តតាកែវ ហើយសព្វថ្ងៃនេះ សុខនា មានជំនឿលើសាសនាគ្រីស្ត។

គ្រីស្តបរិស័ទរូបនេះបានឲ្យដឹងថា កញ្ញាបានស្គាល់ព្រះសហគមន៍កាតូលិកក្នុងឆ្នាំ២០១០ តាមរយៈកម្មវិធីមនុស្សធម៌ផ្សេងៗនៅក្នុងភូមិ។ សកម្មភាពរបស់ព្រះសហគមន៍កាតូលិក បានធ្វើឲ្យកញ្ញាចាប់អារម្មណ៍ចង់ស្គាល់ពីជីវិតរបស់ព្រះយេស៊ូ ហើយក៏បានចូលរួមស្វែងយល់ជាមួយគ្រីស្តបរិស័ទ និងគ្រូអប់រំជំនឿ រហូតដល់ឆ្នាំ២០១៣ ក៏ទទួលបានអគ្គសញ្ញាជ្រមុជទឹកនៅព្រះសហគមន៍កាតូលិកគីរីវង់ មណ្ឌលសកម្មភាពតាកែវ ភូមិភាគភ្នំពេញ។

កញ្ញា ព្រំ សុខនា បានប្រាប់អ្នកនាំសារថា ៖ «ការចែកសេចក្តីស្រលាញ់របស់ព្រះសហគមន៍ធ្វើឲ្យខ្ញុំប្តូរជំនឿខុសពីឪពុកម្តាយ។ ការជួយមនុស្សគ្មានទីពឹង ស្រីមេម៉ាយ.... និងផ្តល់សេចក្តីសង្ឃឹមដោយមិនរើសអើង»។

សព្វថ្ងៃ កញ្ញា សុខនា កំពុងបំពេញការងារជាមួយអង្គការកាតូលិកមួយកន្លែងក្នុងទីក្រុងភ្នំពេញ។ កញ្ញាថា ក្នុងជីវិតជាគ្រីស្តបរិស័ទរបស់ខ្លួន នាងបានជួយនិងជួបការលំបាក ពីក្រុមគ្រួសារផ្ទាល់ និងពីកន្លែងការងារជាដើម។ ប៉ុន្តែដោយសារព្រះវិញ្ញាណតែងតែបានជួយបំភ្លឺ ធ្វើឲ្យខ្លួនសប្បាយចិត្ត និងថ្វាយទុក្ខលំបាកទាំងនោះទៅព្រះជាម្ចាស់។

កញ្ញា ព្រំ សុខនា បានបញ្ជាក់យ៉ាងមុតមាំថា ក្នុងថ្ងៃអនាគត កញ្ញាចង់ថែរក្សាជំនឿឲ្យកាន់តែរឹងមាំ តាមរយៈការបម្រើព្រះសហគមន៍ បម្រើបងប្អូនឯទៀតៗ និងព្យាយាមប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ទៅមនុស្សទៅជុំវិញខ្លួន៕

*បន្តពីទំព័រ-១៤*

សមានចិត្ត និងទឹកចិត្តមនុស្សធម៌ ដោយមិនមានខណ្ឌចែកវាងសាសនាទេ គឺគាត់ធ្វើដើម្បីបានភាពរីកចម្រើននៃមនុស្សជាតិ។ គាត់មកដាំពូជដែលមាននៅក្នុងស្រុកខ្មែរដើម្បីប្រយោជន៍ខ្មែរ»។



ចំពោះអ្នកស្រី ម៉ែន ថារី ដែលជាគ្រីស្តបរិស័ទ និងប្រធានអង្គការមួយបានបង្ហាញពីការសោកស្តាយ ដោយសារបាត់បង់លោកតូនីលឿនពេក។ អ្នកស្រីបានបន្តថា លោកជាមនុស្ស ជាបូជាចារ្យ ដែលធ្វើការហ្មត់ចត់ និងចូលចិត្តណែនាំលើកទឹកចិត្ត។ តាំងពីឆ្នាំ១៩៩២មក មានអារម្មណ៍កក់ក្តៅ ដោយគាត់ចូលចិត្តជួយ និងផ្តល់ឱកាសដល់ក្មេងៗ យុវជន។ គាត់ចូលចិត្តអ្វីដែលយើងសប្បាយចិត្តនឹងធ្វើ។

អ្នកស្រីថារី បានសង្កត់ធ្ងន់ថា ៖ «ខ្ញុំស្រឡាញ់គាត់ ព្រោះគាត់ច្បាស់លាស់។ ការបាត់បង់នេះប្រៀបបាននឹងការបាត់បេះដូង។ ខ្ញុំអារម្មណ៍ហេងហាង»។

ជាមួយគ្នានេះដែរ អ្នកស្រីមានជំជឿថា ព្រះជាម្ចាស់ទទួលយកលោកទៅស្ថានបរមសុខ។ ទោះបីជាមានការសោកស្តាយ ប៉ុន្តែក៏ដល់ពេលវេលា ដែលព្រះជាម្ចាស់ទទួលគាត់។

អ្នកស្រីថា ៖ «នៅពេលយើងអធិដ្ឋានរួមគ្នា គាត់បានឮ និងកំពុងស្តាប់ដោយឃើញគាត់ព្រិចភ្នែក។ ខ្ញុំមិនដែលភ្លេចទេថា ខ្ញុំបានក្លាយជាគ្រីស្តបរិស័ទក្នុងឆ្នាំ២០០៣ ដោយសារបានឃើញរបៀបរស់នៅរបស់គាត់ដែរ»។

ចំណែក យុវជន សុខ ចាន់នី ដែលជាយុវជននៅព្រះវិហារសន្តសិលាពោធិ៍ចិនតុង បានរៀបរាប់ថា លោកឪពុកតូនី បានជួយដល់យុវជនឱ្យមានឱកាសរៀនសូត្រ។ លោកមានទំនាក់ទំនងល្អជាមួយប្រជាជននៅក្នុងភូមិ។

លោក សុខ ចាន់នី បានប្រាប់ថា ៖ «ក្នុងព្រះសហគមន៍លោកបានជួយច្រើន ទោះបីជាមិនសូវបានស្នាក់នៅក៏ដោយ។ លោកឪពុក ឧស្សាហ៍ជួបជាមួយយុវជន ដើម្បីពង្រឹងជំនឿ ជាពិសេសរូបខ្ញុំផ្ទាល់ លោកឪពុកជួយណែនាំ រិះគិតពីជីវិតនៃការត្រាស់ហៅ ព្រមទាំងជួយឧបត្ថម្ភការរៀនសូត្រផងដែរ»។

លោកតូនី (Fr Toni Vendramin -PIME) ជាបូជាចារ្យកាតូលិក ក្នុងក្រុមសាសនទូត PIME។ លោកប្រសូតនៅថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៤២ នៅបាដូវ៉ េ ប្រទេសអ៊ីតាលី។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៦៩។ លោកបានមកដល់ប្រទេសម្ពុជា ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ១៩៩០ រហូតលោកទទួលមរណភាពក្នុងឆ្នាំ២០២១នេះ៕

# ក្រុមសង្គហៈព្រះសហគមន៍សន្តប៉ូល កោះស្លានៃមណ្ឌលសកម្មភាពកំពត ស្បៀងជូនគ្រួសារធ្វើចត្តាឡីស័ក

*ម៉ានុត ចាន់ សិលា*

ព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ក្រុមសង្គហៈព្រះសហគមន៍សន្តប៉ូល កោះស្លានៃមណ្ឌលសកម្មភាពកំពត ដែលស្ថិតក្រោមការដឹកនាំរបស់លោកបូជាចារ្យ យ៉ាំង លូកា បាននាំយកគ្រឿងបរិភោគនិងស្បៀងមួយចំនួនទៅសួរសុខទុក្ខគ្រួសារដែលជាប់ចត្តាឡីស័កនៅក្នុងភូមិកោះស្លា ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត។

សកម្មភាពទាំងអស់នេះ គឺបង្ហាញពីធម៌មេត្តាករុណាតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងគោលបំណងដើម្បីឱ្យបងប្អូនដែលជាប់ចត្តាឡីស័ក មានអំណរសប្បាយ សេចក្តីសង្ឃឹម ការតស៊ូអត់ធ្មត់ ខិតខំប្រឹងប្រែងព្យាបាលខ្លួនតាមវេជ្ជបញ្ជារបស់ពេទ្យ ហើយក៏ដូចជាពន្យល់បន្ថែមនូវការថែរក្សាអនាម័យ និងគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលដោយការអនុវត្តវិធានការ ៣កុំ និង៣ការពារ ព្រមទាំង៣ថែរក្សារបស់លោកអភិបាល អូលីវីយ៉េ ឱ្យបានខ្ចាប់ខ្លួនផងដែរ។

បងប្អូនទាំងអស់គ្នាពង្រឹងស្មារតីបន្ថែមចំពោះការថែរក្សាអនាម័យ និងកុំភ្លេចខ្លួនជាមួយនឹងជំងឺដ៏កាចសាហាវនេះឡើយ៕





# កញ្ញា ស៊ីម សុផាន់៖ «ព្រះសហគមន៍បង្រៀនយើងឲ្យចេះរស់នៅជាធ្លង់តែមួយ និងចេះលើកលែងទោសឲ្យគ្នា»

*អត្ថបទ៖ ឆាក លាំង*

«អ្វីដែលខ្ញុំចាប់អារម្មណ៍ គឺព្រះសហគមន៍កាតូលិកបង្រៀនឲ្យមនុស្សចេះស្រលាញ់គ្នា ឲ្យតម្លៃគ្នាដោយមិនប្រកាន់ពូជសាសន៍ឬសាសនា» នេះជាការលើកឡើងរបស់កញ្ញា ស៊ីម សុផាន់ វ័យ២៥ឆ្នាំ ជាកូនស្រីម្នាក់ក្នុងចំណោមបងប្អូនស្រី៣នាក់ នៅក្នុងគ្រួសារពុទ្ធបរិស័ទ ដែលមានស្រុកកំណើតក្នុងភូមិព្រៃជើង ស្រុកគីរីវង្ស ខេត្តតាកែវ។

កញ្ញា ស៊ីម សុផាន់ បាននិយាយពីប្រវត្តិជំនឿរបស់នាងដែលជ្រើសរើសជឿលើសាសនាគ្រីស្តនិកាយកាតូលិកថា ដំបូងឡើយនាងបានជឿលើសាសនាព្រះពុទ្ធតាមជីដូនជីតាបងប្អូនឪពុកម្តាយ ដូចប្រជាជនទូទៅដែរ ប៉ុន្តែនៅក្នុងឆ្នាំ២០០៣ វត្តមានព្រះសហគមន៍បានទៅដល់ភូមិដែលនាងបានទៅដល់ភូមិដែលនាងរស់នៅតាមរយៈសកម្មភាពចុះសួរសុខទុក្ខរបស់ក្រុមគ្រីស្តបរិស័ទនិងលោកបូជាចារ្យ។

គ្រីស្តបរិស័ទរូបនេះបានបន្តទៀតថា ក្រោយមកនាងបានចូលរៀនស្វែងយល់ជំនឿលើសាសនាគ្រីស្តពីគ្រូអប់រំជំនឿ បងប្រុសបងស្រី លោកបូជាចារ្យជាច្រើនឆ្នាំ ក៏សម្រេចចិត្តប្តូរមកជាគ្រីស្តបរិស័ទនិងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០១៣នៅព្រះសហគមន៍ព្រះត្រៃឯកគីរីវង្ស ក្នុងមណ្ឌលសកម្មភាពតាកែវ ខេត្តតាកែវ។



កញ្ញាស៊ីម សុផាន់ បានថ្លែងថា៖ «មូលហេតុដែលខ្ញុំប្តូរជំនឿដោយសារព្រះសហគមន៍បង្រៀនឲ្យចេះរស់នៅជាធ្លង់តែមួយ មិនប្រកាន់ច្រើន និងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក»។

កញ្ញាបានបន្តទៀតថា ក្រោយទទួលអគ្គសញ្ញាជ្រមុជទឹកប្តូរទៅជាគ្រីស្តបរិស័ទពេញលក្ខណៈ ជីវិតរបស់នាងមានការផ្លាស់ប្តូរប្រែជាមានភាពរឹងមាំច្រើនជាងមុន។ វត្តមានរបស់ព្រះយេស៊ូក្នុងជីវិតរស់នៅប្រចាំថ្ងៃជួយផ្លាស់ប្តូរនាងទាំងស្រុងដែលពីមុននាងធ្លាប់តែជាក្មេងម្នាក់រឹងទទឹង មិនសូវស្តាប់បង្គាប់ឪពុកម្តាយ និងមិនសូវខ្វាយខ្វល់ពីមនុស្សនៅជុំវិញខ្លួន បែរមកជាប្រតិបត្តិនិងគោរពពួកគាត់ទៅវិញ។

កញ្ញា ស៊ីម សុផាន់ បានរស់នៅជាជីវិតជាគ្រីស្តបរិស័ទតាំងពីឆ្នាំ២០១៣ រហូតមកទល់សព្វថ្ងៃនេះដោយរស់នៅក្នុងចំណោមបងប្អូន ពុទ្ធបរិស័ទជាច្រើន ដែលជាហេតុនាំឲ្យនាងទទួលបានបទពិសោធន៍ជាច្រើននៅក្នុងសង្គម ទាំងការគោរពស្រលាញ់ និងការមើលងាយពីមនុស្សជុំវិញខ្លួន។

គ្រីស្តបរិស័ទរូបនេះបានរៀបរាប់ទាំងអួលដើមកថា ៖ «ពេលខ្លះ ខ្ញុំចង់បាក់ទឹកចិត្ត ចង់បោះបង់ជំនឿចោល ដោយសារពាក្យមើលងាយពីបងប្អូន តែដោយសារមានព្រះវិញ្ញាណជួយបំភ្លឺធ្វើឲ្យខ្ញុំមានកំលាំង និងសេចក្តីក្លាហានក្នុងការបន្តជីវិតដោយជឿលើព្រះយេស៊ូបន្តទៀត»។

ទោះបីជាការរស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទទើបតែ៧ឬ៨ឆ្នាំក៏ពិតមែន តែកញ្ញា ស៊ីម សុផាន់ បានតាំងចិត្តថា សម្រាប់ជីវិតរបស់នាងនាពេលអនាគតគឺមិនមានអ្វីច្រើននោះទេ ដោយគ្រាន់តែចង់រស់នៅប្រកបដោយសេចក្តីសុខ និងព្យាយាមបន្តជំនឿនេះទៅមនុស្សនៅជុំវិញខ្លួនឲ្យបានស្គាល់ពីវត្តមានរបស់ព្រះយេស៊ូក្នុងជីវិតរបស់គេម្នាក់៕




លោកឪពុក Fernando បានបញ្ចប់បេសកកម្មបម្រើព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបន្ទាប់ពីលោកបានបម្រើព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ អស់ពីកម្លាំងកាយចិត្តជាច្រើនឆ្នាំមកហើយ។ ការចាកចេញទៅបន្តការសិក្សារបស់លោកឪពុក Fernando គឺជាការបាត់បង់ធនធានមនុស្សម្នាក់ដ៏សំខាន់សម្រាប់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ សូមបងប្អូនអធិដ្ឋានពិសេសសម្រាប់លោកឪពុកនៅក្នុងការបំពេញបេសកកម្មថ្មីសម្រាប់ព្រះជាម្ចាស់ផង៕





សកម្មភាពលោកបូជាចារ្យ និងបងស្រីក្នុងតំបន់កំពង់ចាមបានដឹកនាំយុវជននៃព្រះសហគមន៍កាតូលិកកោះរការរួមជាមួយយុវជនៃព្រះសហគមន៍ព្រែកពោធិ៍ ទៅសួរសុខទុក្ខ និងអធិដ្ឋានសម្រាប់អ្នកម្នាក់មានជំងឺមហារីកដំណាក់កាលចុងក្រោយ ស្ថិតនៅក្នុងភូមិរការទ្វារ ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម៕

ក្រុមសង្គហៈព្រះសហគមន៍សន្តយ៉ូសែប ជុំគិរី ដឹកនាំដោយលោកបូជាចារ្យ លូកា (Tavola Gianlaca) បានចូលរួមចែកគ្រឿងឧបភោគបរិភោគជូនដល់បងប្អូនដែលកំពុងជួបទុក្ខលំបាក ចំនួន៥១គ្រួសារ។ ក្នុងនោះក្នុងមួយគ្រួសារទទួលបានអង្ករ២៥គីឡូក្រាម ទឹកត្រី២ដប ប្រេងឆា២ដប និងប្រាក់បន្ថែមម្នាក់ៗចំនួន១០,០០០រៀល ដោយប្រព្រឹត្តក្នុងបរិវេណព្រះសហគមន៍សន្តយ៉ូសែប ជុំគិរី។ ការផ្តល់គ្រឿងឧបភោគបរិភោគនេះ ធ្វើឡើងជា២វេន គឺពេលព្រឹកនិងពេលរសៀល ដើម្បីរក្សាការពារកុំឱ្យមានការឆ្លងរាលដាលជំងឺកូវីដ-១៩ ៕ ដោយ៖ លិន សីហា (អ្នករាយការណ៍ព័ត៌មានពីមណ្ឌលសកម្មភាពកំពត-កែប)









លោកឪពុក សំណាង ជាបូជាចារ្យទទួលខុសត្រូវសាលាដុនបូស្កូខេត្តកែប បានដឹកនាំការអធិស្ឋាន ដើម្បីសន្តិភាព យុត្តិធម៌ បរិស្ថាន និងការបញ្ចប់នៃជំងឺរាតត្បាតកូវីដ-១៩ នៅក្បែរមាត់សមុទ្រក្នុងសាលាដុនបូស្កូខេត្តកែប៕







# *យើងជាគ្រួសារតែមួយ!*

ព្រះសហគមន៍កាតូលិករបស់យើងជាគ្រួសារដ៏ធំធេងមួយ នៅក្នុងទុក្ខលំបាកកូវីដ-១៩នេះ
យើងយកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក និងចែករំលែកសេចក្ដីស្រលាញ់ដល់បងប្អូនរបស់យើង។
ព្រះសហគមន៍ជួយដល់អ្នកត្រូវការអំឡុងពេលដែលយើងរួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩។









